ឧកញ៉ាសុត្តន្តប្រីជា ឥន្ទ

LIBRARY

# និរាសនគរវត្ត

ភ្នំពេញ

ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ

ព.ស ២៥៤១

៣១៥.៣៩០

ពាក្យកាព្យ

# និរាសនគរវត្ត

ឧកញ៉ាសុត្តន្តប្រីជា ឥន្ទ
រៀបរៀង

បោះពុម្ពគ្រាទី ២ ចំនួន ២.០០០ ច្បាប់
ដោយថតចម្លងតាមច្បាប់បោះពុម្ពគ្រាទី ១ ឆ្នាំ ១៩៦៩

ពុទ្ធសាសនបណ្ឌិត្យ INSTITUT BOUDDHIQUE

បណ្ណាល័យ LIBRARY BUDDHIST INSTITUTE
៣៣២៧/៩៧

ភ្នំពេញ
ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ
ព.ស ២៥៤១ គ.ស ១៩៩៧

# UN PELERINAGE A ANGKOR

**Poème composé par**

**OKNHA SUTTANTAPRIJÃ IN**

Deuxième Edition

2.000 Ex.

PHNOM PENH

Edition de l'Institut Bouddhique

1997

# សេចក្ដីបញ្ជាក់
# ចំពោះការបោះពុម្ពឡើងវិញ

សៀវភៅ « **និរាសនគរវត្ត** » នេះ ត្រូវបានបោះពុម្ពឡើងវិញ ដោយបានទទួលការឧបត្ថម្ភពីអង្គការជំនួយសូត្តូស៊ូជប៉ុន (JSRC) និងពីក្រុមប្រឹក្សាពិភពលោក ដើម្បីសាសនា និងសន្តិភាព (WCRP) ។

ពុទ្ធសាសនបណ្ឌិត្យ ទុកឱកាសជូនអ្នកអានពិនិត្យ សិក្សាដោយខ្លួនឯងនូវទេពកោសល្យនៃអ្នកនិពន្ធពាក្យកាព្យនិរាសនគរវត្ត ដែលត្រូវបានបោះពុម្ពឡើងវិញនាពេលនេះ ។

គោលបំណងនៃកាបោះពុម្ពឡើងវិញនៃសៀវភៅនេះ គឺ :

- ដើម្បីថែរក្សាទុកឱ្យបន្តគង់វង្សនូវស្នាដៃអក្សរសិល្ប៍របស់ខ្មែរពីបុរាណ កុំឱ្យបាត់បង់ ។
- ដើម្បីទុកឱ្យកូនចៅខ្មែរជំនាន់ក្រោយបានស្គាល់ បានសិក្សារៀនសូត្រ ។
- ដើម្បីទុកឱ្យអ្នកតែងនិពន្ធក្រោយៗ បានសិក្សាប្រៀបធៀបស្នាដៃរបស់ខ្លួន ។

វីការបោះពុម្ពឡើងវិញលើកនេះ ធ្វើឡើងដោយថតចម្លងពីសៀវភៅច្បាប់ដើមទាំងស្រុង ។ ហេតុនេះ ប្រសិនបើមានកំហុសអក្ខរាវិរុទ្ធក្ដី កំហុសក្នុងការរៀបរៀងឃ្លាក្ដី នោះគឺជាលក្ខណៈដែលមានក្នុងច្បាប់ដើមពីមុនមក ។

ពុទ្ធសាសនបណ្ឌិត្យ សូមអភ័យទោសជាមុន ចំពោះកង្វះខាតផ្សេងៗដែលអាចនឹងកើតមានដោយអចេតនា ក្នុងការបោះពុម្ពឡើងវិញនេះ ។

ភ្នំពេញ, ខែ កក្កដា ឆ្នាំ ១៩៩៧

ពុទ្ធសាសនបណ្ឌិត្យ

# អារម្ភកថា

ពុទ្ធសាសនបណ្ឌិត្យ បានបោះពុម្ពផ្សាយអត្ថបទ "ពាក្យកាព្យ ពិភាសជគវត្ត" នេះ រួចម្តងមកហើយ គឺផ្សាយក្នុងទស្សនាវដ្តី កម្ពុជសុរិយា ឆ្នាំ ១៩៣៤ លេខ ៧-៨-៩ ។ កាលគ្រានោះ អ្នកនិពន្ធនៃពាក្យកាព្យ បានយកសំណៅមកប្រគល់ឲ្យពុទ្ធសាសនបណ្ឌិត្យ ចុះផ្សាយ ដោយលោកជាអ្នកពេញចិត្តក្រៃលែងចំពោះអក្សរសាស្ត្រ ។ យើងក៏សូមថ្លែងអំណរដ៏លើសលុបចំពោះកវីរូបនេះផង ។

ពពួកអ្នកសិក្សាស្រាវជ្រាវ និងអ្នកនិយមពាក្យកាព្យឃ្លោងដែលធ្លាប់អាន ធ្លាប់សិក្សាអត្ថបទនេះ ជាច្រើននាក់ បានមកសុំឲ្យយើងបាត់ចែងយកមកបោះពុម្ពសាឡើងជាថ្មីម្តងទៀត ធ្វើជាសៀវភៅមួយដោយឡែក ។ យើងក៏ចាត់លោក **លី.ធាមតេង** អ្នកស្រាវជ្រាវប្រចាំវិជ្ជាឋានយើង ឲ្យរើអត្ថបទនេះមកផ្ទៀងផ្ទាត់សេចក្តី និងតម្រូវអក្ខរាវិរុទ្ធដែលភ្លាំងភ្លាត់ កាលបោះពុម្ពលើកមុន ឲ្យបានត្រឹមត្រូវ ហើយនិងធ្វើនយលក្ខណៈខ្លះពន្យល់ពាក្យណាដែលពិបាក ៗ ដូចជាពាក្យដែលគេធ្លាប់ប្រើតែកាលពីសម័យនោះ, ពាក្យខ្លះក្លាយមកពីភាសាបរទេស និងពាក្យខ្លះទៀតជាសំដីអ្នកស្រុកនៅភូមិភាគបាត់ដំបង - សៀមរាប - ហើយដែលអ្នកខេត្តដទៃទៀត

ពុំសូវធ្លាប់ឮ ៗ ការបន្ថែមនយលក្ខណៈបែបនេះ +ដើម្បីជួយសម្រួលអ្នកអានទូទៅ ជាពិសេសអ្នកសិក្សាដែលមានវ័យនៅក្មេង ៗ ឲ្យបានងាយយល់ អាចឈានជាប់ន័យនិងរសខ្លឹមសារ ក្នុងពាក្យកាព្យនេះ បានច្បាស់លាស់ ៗ ប៉ុន្តែទោះបីជាខំយ៉ាងនេះក្ដី ក៏គង់នៅមានខ្វះចន្លោះច្រើនទៀតមិនខាន យើងក៏សុំអភ័យទោសចំពោះលោកអ្នកអាន អំពីការខ្វះខាតភ្លាំង-ភ្លាត់ខ្វះក្រៅចេតនានេះ ផងដែរ ។

គោលបំណងធំរបស់យើង គឺការបំផុសនូវពាក្យកាព្យ និង ធ្វើឲ្យលេចភ្លឺត្រចះត្រចង់ឡើងនូវសម្ផស្សកាព្យ សំនួនវោហារ ព្រមទាំងអត្ថ-រសជាខ្លឹមសារ ដែលកវីបានបង្កប់នៅលាយឡំក្នុងអត្ថបទនេះ, ព្រោះថារបស់ល្អយ៉ាងណាក៏ដោយ បើគេពុំបានលាតត្រដាងឲ្យឃើញរូបឆោមទេ ស្ថិតនៅលាក់ខ្លួនដោយកៀនកោះ, របស់នោះឯងក៏ពុំមានប្រយោជន៍អ្វីឡើយ ហើយជាការឥតអំពើថែមទៀត ។ ដូច្នេះ យើងត្រូវតែព្យាយាមលើកយកមកផ្សាយជាសាធារណៈ ទើបបានជាការសិក្សា យកជាបទពិចារណា បង្កើនស្មារតីចេះដឹង ឲ្យកាន់តែបរិបូណ៌ឡើង ដើម្បីជាហិត-ប្រយោជន៍ចំពោះអ្នកអាន អ្នកសិក្សាទូទៅ ។

ពិតមែនហើយ អត្ថបទនេះ អ្នកនិពន្ធអធិប្បាយតាមការពិតទាំងស្រុង គឺលោកឃើញយ៉ាងណា ឮយ៉ាងណា គិតយល់យ៉ាងណា លោក

ក៏សរសេរយ៉ាងនោះ, ប៉ុន្តែធម្មតាការពិតពេក រមែងប៉ះពារទៅលើនេះលើនោះ នាំឲ្យកើតរង្កៀសខ្លះ ក៏មិនខានដែរ ។ តែណ្ហើយចុះ យើងសុំចម្លងទាំងស្រុងតាមអត្ថបទដើម ឥតហ៊ានកែ ហ៊ានបំផ្លើស មួយម៉ាត់ណាឡើយ ត្បិតចង់រក្សាលក្ខណៈដើមឲ្យនៅបរិសុទ្ធ, ហេតុការណ៍ចាស់ ៗ ក៏ឲ្យនៅគ្រប់ សម្រាប់ឲ្យអ្នកអាន អ្នកសិក្សាធ្លុះមើលឃើញរបៀបរបបការរស់នៅនៃស្រុកយើង និងចិត្តគំនិតរបស់អ្នកស្រុកយើងកាលពីសម័យនោះ ៗ ដូច្នេះ បើលោក-អ្នកអានឆ្ងល់ត្រង់ណា, ឃើញពុំសមត្រង់ណា ក៏សុំរិះគិត យកកាលទេសៈធ្វើជាប្រមាណ ទើបកាត់សេចក្តីសង្ស័យទាំងនោះបាន ។

ទីបំផុត ពុទ្ធសាសនបណ្ឌិត្យ សូមថ្លែងសេចក្តីកោតសរសើរយ៉ាងជ្រាលជ្រៅ ចំពោះសន្តានចិត្តលោកកវី សុត្តន្តប្រីជា **ឥន្ទ** ដែលបានទុកស្នាដៃជាច្រើនក្នុងអក្សរសាស្ត្រ និងវប្បធម៌ជាតិ រាប់ថាជាអ្នកប្រាជ្ញអក្សរ-សាស្ត្រមួយរូបយ៉ាងឆ្នើម ក្នុងដើមសតវត្សទី ២០ ។

ភ្នំពេញ ថ្ងៃទី ៣០ មីនា ១៩៦៧

ពុទ្ធសាសនបណ្ឌិត្យ

ពាក្យកាព្យ

# និរាសនគរវត្ត

# និរាសនគរវត្ត

១ និរាសនគរវត្តនគរសែនវិចិត្ត

កាលចេញចាកលោកបរសមរមិត្រ
កែវដីកាគូដវិតកិសម័យ ៗ

ដោយមានការបក្រពង្សវង្សក្រស័ត្រ
ស៊ីសុវត្ថិព្រះកែវហ្វាសុទ្យាវៃ
ព្រះចៅក្រុងកម្ពុជាធិបតៃ
មានព្រះទ័យហ្វាយប៉ង់ពោធិញ្ញាណ ៗ

ទ្រង់យាងមកនគរវត្តសមោសរ
ចាត់បដិសន្ថារណ៍ទីបុរាណ
បរិច្ចាគរាជទ្រព្យប្រដាប់ទាន
បំពេញញាណសម្ពោធិបញ្ញា ៗ

កំណត់ថ្ងៃយាងនោះចុះខាងខ្នើត
ប្រាំបួនកើតភទ្របទមាសា
ថ្ងៃព្រហស្បតិ៍លេខប្រាំឆ្នាំរកា
ពេលសុរិយោជ្រេសែងព្រះរង្សី ៗ

លោកចៅហ្វាយខេត្រស្រុកព្រះដំបង

ជានាយកងចាត់ការរាជការថ្មី

ព្រមទាំងលោកកុម្មិសែរអធិបតី

ចិត្តភក្តីត្រេកត្រង់ទាំងទ្វេហារ ៗ

រៀបចាត់ចែងតែងតួតាមទំនួល

ទៅទទួលព្រះបមចៅច័ក្រា

លោកក៏យកខ្ញុំបាទទៅផងណា

ព្រោះមេត្តាចង់ឲ្យយល់ទបុរាណ ៗ

គ្រាន់ទឹងខ័តទទឹងប្រសាសន៍លោក

ក្រែងជួនស្មោកកើតទោសមោះដល់ប្រាណ

ខំតែកាត់ចិត្តលះលាកល្យាណ

គូបុរាណកាលកម្មចាំចាកចរ ៗ

ដល់ពេលផ្ទុំលោកធំចុះចាកស្ថាន

ឡើងរថយានទឹមសេះដ៏បវរ

សារថីជំនាញទាញបើកបរ

បត់បរចុះដល់កំពង់ទឹក ៗ

ពួកកងការបារាំងតាំងខ្មែរយួន
សឹងតែងខ្លួនជូនដំណើរអឹកធឹក
ពួកតាហានជើងខ្មៅប្រចាំសឹក
ដង្ហែគ្រឹកចុះកប៉ាល់ជាស្រេច ៗ
នាយតៃកុងទាញខ្សែរបើកង
លាន់បីដងម៉ាតឡូស្រាយយុថ្កា
សទឹមពេញកំបេញបមឧត្តរា
តាមគង្គាហូរត្រង់តម្រង់បរ ៗ
តៃកុងយួនបេះក្បួនបង្កួតត្រង់
កាត់តម្រង់តាមជ្រោយប្រាំងសាគរ
បត្រក៏វិលវាយទឹកពន្ធឹកខ្ទរ
អ្នកនគររត់មើលគ្រប់លំនៅ ៗ

កប៉ាល់លឿនដល់គយខ្ញុំគយគន់
យល់ដំបន់មេគយប្រចាំផ្លូវ
មានសសរគោមតាំងមុខលំនៅ
មើលៗ ទៅទីលំនៅមិនសមសក្តិ ៗ
ផ្ទះរយោកតាគរយោលស្ទើររយោង

ភាពជាខ្មែរកែជាកេង៍យោង៍ជាថ្នាក់
ឱគយនេះយ៉ាងជាគ្នាខាត់ប្រាក់
គ្រាន់តែត្រួតមើលអ្នកចូលចេញក្រៅ ៗ
នឹងមានហូតពន្ធដារការក៏ទេ
គ្រាន់តែគេចូលប្រាប់ក៏ហួសទៅ
ឱគយនេះអត់ពន់ធន់តាំងនៅ
ធ្វើតែស្រូវដាំច្បារចំការស៊ី ៗ
ពជការសៀមតាំងគយនៅចុងស្រុក
ពុំឃើញមានទំនុកឲ្យហូតអ្វី
កោតមេគយនៅចាំជាប្រក្រតី
ពជការថ្មីលោកលើកពុំបំរុង ៗ
ឱអ្នកគយគេធ្វើចំការស្រែ
មិនជួញប្រែយ៉ាងយើងអ្នកស្រុកក្នុង
កោតគេរកធនធានគ្មានកោងកុង
ស៊ូកក់ផុងដិតកាយក៏តតថៅ ៗ
ស្តាយតែរូបនារីពាងស្រទៀវ
ចុះស្ទូងស្រូវត្រូវកំដៅព្រះសុរិយា

ដិតទាំងដីកក់ផងហ្វងក្រ្ដា
អនិច្ចាជាតិអ្នកក្រត្រដរទៅ ៗ
ប្រសិនមានមាសប្រាក់និងសក្តិយស
ស៊ីក៏ខ្ពស់ដេកក៏ខ្ពស់ឥតមោះមៅ
បំរុងលាបទឹកអប់និងប្រេងម្សៅ
កាល់ចាប់ខ្មៅតែងខ្លួនឲ្យនួនល្អង ៗ
តែងប្រកួតអួតគោមប្រលោមប្រុស
ត្រកូលខ្ពស់យល់ហើយមិនកន្ទង
នេះមកត្រូវកំដៅកក់ផង់ផង
ទឹងស្នាលស្នងបងចិត្តស្និទ្ធម្ដេចបាន ៗ
គន់ ៗ គិតអាណិតនារីតូច
កើតក្នុងពូជហីនយសខុសសន្តាន
តោងត្រដរទៀយយ៉ាកលំបាកប្រាណ
ទម្រាំបានមាសប្រាក់ឆ្លាក់ដល់ចាស់ ៗ
ចាស់ហើយតើទឹងតែងតួម្ដេចល្អ
ប្រុសនឹងតថ្ងៃទិញយល់ក្រណាស់
ឃើញជាចុះថ្ងៃថោកល្មមបោកប្រាស

ការសង្វាសនឹងសង្វាតជាប់សង្វែង ៗ
សំណាងទន់ក្រងទតោងជន់អត់
ក្ដីនឿយហត់រកស៊ីតាមដំណែង
គេអ្នកមានគេតែងកាយចិញ្ចែង
មិនដូចខ្លួនន្លួនឯងកក់ស្រមក ៗ

អង្គុយគន់នារីឲ្យកិសរង់
កប៉ាល់លឿនដល់ប៊ុងអន្សង់សក
ស្ទឹងកំពូបបត់កំទ្វីបប្លួនប្រែក
សំណាក់កកដេរដាសពាសពេញស្ទឹង ៗ
នាយតៃកុងកាប់ច័ក្រពុះសំណាក់
ច័ក្រកំកាត់ខ័តណែនកប៉ាល់នឹង
ពួកម័តឡូបាក់ថ្មោលដោលទទឹង
ច័ក្រកំរង់ផាត់វិលកប៉ាល់ក ៗ
ពួកអ្នកថ្មោលរឹងដោលសំណាក់ញែក
កប៉ាល់ជ្រែកវែកប្រាណបានមួយគ្រា
សំណាក់ពុកកប៉ាល់ជាប់ចក្រខំពារ
មើលទៅនាច័ក្រពើសំណាក់រឹត ៗ

ខ្ញុំគន់មើលសំណាត់ក៏ត់កប៉ាល់
ដូចរាគកាល់រូបកាយចុះបរិត
ពុំឲ្យរូបរើរួចពីទីល្ងិត(១)
បំបាំងបិទត្រៃលក្ខណ៍បាត់ស្ងើ ។
កាមរាគរោលរឹតសុត្តក្នុងលោក
ឲ្យសត្វនៅសៅសោកក្នុងលោកិយ៍
រាងកប៉ាល់ដូចរូបយើងប្រុសស្រី
ប្រាជ្ញាខ្ញុំមិនយល់កលត្រៃលក្ខណ៍ ។
ស្ទាបចក្រគឺបញ្ញាឆ្ការកកាប់កាត់
កងសំណាត់គឺរាគឲ្យលាកធ្លាក់
បានរួចចេញចាកទុក្ខសោករោគរាក់
អាស្រ័យចក្រគឺបញ្ញាក្លៀវក្លាហាន ។
គ្រឿងកប៉ាល់ដូចកលអាការយើង
ដីទឹកភ្លើងខ្យល់គឺធាតុបួនស្ថាន
ចង្កូតគឺសតិរំឭកបាន
ថ្នាលដោលប្រានគឺសមាធិចិត្តដាក់ ។

---

១ — តាមត្រូវ គឺ ងងឹត តែវិតេះ តម្រូវតាមពាក្យឃ្លង ។

សំណាត់គឺបាបធម៌និវរណៈ
បិទបាំងកៈមិនឲ្យយល់ត្រៃលក្ខណ៍
ទឹកហូរវល់ដូចកល់សង្សារច័ក្រ
ឲ្យសត្វធ្លាក់នៅក្នុងអន្ទង់កាម ៗ
ទុអនិច្ចារូបកាយមិនណាយលាក
អំពីពគនៅតែវឹងក្រឡឹងតាម
បានជាផល់ទុក្ខមកយំរហាម
ព្រោះមិនតាមពុទ្ធកិច្ចភ្លេចស្មារតី ៗ
ខ្ញុំគិត ៗ គួរសង្វេគរូបអាត្មា
មកលុះចុះតណ្ហាការលោកិយ៍
ឃើញធម៌ហើយក៏នៅតែនឹកស្រី
ជាចំណីពគរឹតបិទមុខមាត់ ៗ
កាច់មិនបានព្រោនមិនបែរវឹងតែបិទ
អនាថចិត្តអាណិតចៅមកប្រោសព្រាត់
គ្រាន់នឹងតាមព្រះបន្ទូលជាបន្ទាត់
លោកិយ៍អត់កត់មិននឹងទទឹងគាង ៗ

---

យកធម៌ព្រះមកលះភ្លើងមិនឈប់

ងងឹតឈឹងដូចយប់មិនយល់ភង
ឱលោកិយ៍លះគ្រគ្រាន់តែព្រាង
ដូចគេលាងព្រៃខ្មៅត្រូវដ័រទឹក ៗ
ទំផុសលាងយ៉ាងណាមិនឡើងពណ៌
ជាតិជាដ័រជាប់នៅខ្មៅស្រមឹក
ដូចកិលេសជាប់សត្វចាត់ជាសឹក
អ្នកកុំទឹកគិតលាងឲ្យជ្រះបាន ៗ
ដូចរូបខ្ញុំខំលះរឹតតែរឹង
ទប់មិនទឹងតាំងមិននៅផ្លូវកម្មដ្ឋាន
អង្គុយគិតយកធម៌ទូន្មានប្រាណ
ដូចគេប្រានសំណាត់សាត់មួយគ្រា ៗ
ដល់ហួសទៅសំណាត់សាត់មកវិញ
ប្រមូលពេញដូចដើមណា នួនណា
ឱសំណាត់នេះប្រៀបដូចតួតណ្ហា
ទឹងកាប់ឆ្ការយ៉ាងណាក៏ណែនវិញ ៗ
គន់សំណាត់សាត់ជាប់ពុងចំការ
ទាំងខ្ចាចក្តែខ្ចាចឆ្នាត្រាពាសពេញ

ខ្លះល្អួយខ្លះប្រែះពោះវៀនចេញ
ក្អែកត្មាតដេញគ្នាស៊ីជាកក្រា ។
ខ្ញុំគន់មើលសាកសពចំណីក្អែក
គិតសង្វេគដល់រូបនៃអាត្មា
ឱសត្វក្អែកមកលុះក្តីមរណា
សូន្យជីវ៉ាគេបោលបណ្តែតទឹក ។
កាលពីរស់គឹងកាចអំណាចមាន
សត្វតិរច្ឆានជួបគ្នាមិនហ៊ានចឹក
ដល់ខ្លួនស្លាប់គេអូសបណ្តែតទឹក
ក្អែកត្មាតត្រឹកចឹកស៊ីមិនគ្រាន់ឡើយ ។
ឱអនិច្ចាសង្ខារសត្វទាំងឡាយ
តែបែកកាយរំលាយខន្ធទៅហើយ
គេក៏កើតខ្ពើមឆ្អើមពុំជិតឡើយ
យើងគេអើយគួរគិតផ្លូវអនិច្ចា ។
ខ្ញុំបាទខំសង្វេគសាកអសុក
ពាគមិនឈប់ចេះតែកេលទាំងរូបា
ទឹកតែទៅដល់ពៅកែវសុតា

អនិច្ចាថាតែមាត់ចិត្តមិនចាំ ។
អសុកដប់សម្រាប់លោកលាងលាក
កំចាត់រាគចរិតចិត្តបឋម
ព្រះយោគីលោកសមាធិចុះអារម្មណ៍
បែកតែទំពុំចំអារម្មណ៍ឡើយ ។
យកសពផ្ដែមកប្រែទឹងរូបកាយ
មិនរសាយណាយរសោះណាលោកអើយ
ធ្វើម្ដេចហ្ន៎បានលោកឯណាអើយ
ជាកោះត្រើយណែផ្លូវឲ្យទានរ៉ា ។
មួយសង្ស័យទឹងពាក្យ "អន្សងសក"
ពាក្យប្រែបកដូច្នេះគួរសង្កា
សត្វអន្សង់ រាសកពីកាលណា
បានជាមកសញ្ញាឈ្មោះយ៉ាងនេះ ។
សត្វអន្សងមិនដែលសករសោះទេ
នេះហេតុអ្វីក៏គេហៅដូច្នេះ
ឬគេឃើញសំណាកនៅនេះអេះ
បានជារិះត្រិះនាមមកឥឡូវ ។

រឹងពិនិត្យមិនយល់សែនឆ្ងល់ពេក
ការឈ្មោះថ្វកនាមសត្វពាត់មិនត្រូវ
អន្ទងសក លោកណាឲ្យនាមហៅ
បានជានៅនាមជាប់ឥឡូវនេះ ៗ
តែបើគិតគួរកោតលោកបុរាណ
ចេះគិតអានសន្ធតនាមយ៉ាងនេះ
ទីព្រៃសោះចេះឲ្យឈ្មោះប្ដោះប្ដេះ
ពេញជាចេះកំណត់កត់នាមនៅ ៗ
អង្គុយគិតចិត្តភ្ញើនរំភើយខ្យល់
កប៉ាល់គ្រឿនលឿនដល់ព្រែកក្របៅ
ទឹកក៏នឹងពុំហូរបុះទៀតទៅ
ឃើញទឹកខ្មៅថ្លាយង់ឥតពកគា ៗ
ក៏ដឹងថាជាទឹកទន្លេដល់
ទឹកស្ទឹងកល់ហូរទល់ប្រសព្វគ្នា
បានជានឹងពុំហូរត្រឹមនោះណា
នឹកសង្កា ព្រែកក្របៅ ហៅសែនឆ្ងល់ ៗ
ព្រែកនេះតើបែកមកពីណាអេះ

ឃើញតែចុងត្រឹមនេះមិនឃើញគល់
ឬព្រែកនេះទំនាបជាភាពទាល់
គួរពិភាល់ចិត្តណាស់ព្រែកក្នុងព្រៃ ៗ
ព្រែកនេះតើគេជីកឬកើតឯង
លោកមកតែងនាមក្រពៅនៅច្នេះនៃ
ខ្ញុំពីគ្រោះមិនអស់ក្តីសង្ស័យ
កប៉ាល់លឿនដល់កន្ត្រៃថ្ងៃក៏ទាប ៗ
ព្រែកកន្ត្រៃកាត់ត្រង់ត្រូវកញ្ឈាះ
ទីស្រឡះគេដើរបានរៀងពប
ព្រៃដុះល្បោះ(១) ចុះតាមទីទំនាប
អ្នកស្វែងលាភគេត្រីអាស្រ័យបាន ៗ
ព្រែកកញ្ឈាះទីស្រឡះគេដើរដល់
ស្រុកមង្គលបុរីជាជ័យឋាន
គិតៗទៅ គួរកោតលោកបុរាណ
ចេះគិតអានចាត់ព្រែកឈ្មោះថ្លៃក្លា ៗ
មួយសង្ស័យទ៏ងនាមកន្ត្រៃនេះ

១— តាមត្រូវ គឺ របោះ ។

នរណារិះថាត់ឈ្មោះទុកច្នេះណា
វិស័យទីជាស្ថានព្រៃព្រឹក្សា
មកសញ្ញាហៅកន្ត្រៃសង្ស័យស៊ុន ។
ឬកន្ត្រៃលោកណាធ្លាក់នៅនេះ
បានជារិះយកនាមនេះមកគុណ
ឬមានជាធកន្ត្រៃគេនៅមុន
ឬអ្នកបុណ្យឲ្យឈ្មោះព្រោះជាប់គ្នា ។

រំពឹងគិតមិនយល់ដល់ព្រលប់
ពេលក៏យប់ម៉ោងមួយដល់បាក់ព្រា
តែកុងទាញសប្ដេឡើងបីសា
ប្រាប់នាវាឲ្យបៀសកប៉ាល់ចូល ។
លុះចូលដល់ស្ពានផែមុខសាលា
បោះយុថ្កាចតចងតាមទំទួល
លោកមានសៀ(១)នាយគយចិត្តស្រោះស្រួល
មកទទួលលោកធំ(២) ទៅគ្រឹហា ។

---

១— មកពីភាសាបារាំង Monsieur ។

២ – លោកធំ ជាពាក្យដំនាន់នោះហៅចំពោះ Résident បារាំង ដែលនៅត្រួត ប្រចាំទីរួមខេត្តនីមួយៗ ។

ចៅភ្នាក់ងារនាំឧសផ្ទុកកប៉ាល់
ដាក់ពេញទាល់ទាំងល្វែងនៃនាវ
លោកបុល័ដ្ឋតាត់លៀងមួយវេលា
ទាំងអស់គ្នាគេសែនសប្បាយចិត្ត ។
តែខ្ញុំមួយព្រួយប្រាណរំខានសល់
ចង់តែដល់បានយល់បមបពិត្រ
អស់ភជការទឹងបានវិលស្ដានស្ដិត
មិនដឹងគិតកែផ្លូវឲ្យត្រូវឡើយ ។
អង្គុយគិតដើរគិតដូចពុលផ្សិត
ភគក៏តែភេលភលភមិនស្បើយ
លុះដល់ម៉ោងពីរខ្យល់រំភើយ
គ្រាន់លំហើយក្តីទុក្ខពីមុខបាន ។
មើលទៅស្ទឹងបាក់ព្រោជាធ្លាធំ
ពួកអ្នកឈ្មួញមកជុំទាំងបីដាន
មួយគឺស្ទឹងមង្គលបូរីហាន
ពីរគឺដានព្រះដំបង បីទន្លេ ។

ទីស៊ឹងនោះកាលកផ្សសៀមចាយចែក
ចាត់ឲ្យហៅ សាមយ៉ែកភា សាគេ
ព្រោះដានបីចេញទៅមាត់ទន្លេ
បើតាមគេឃើញត្រូវជាផ្លូវបី ។
ឯពាក្យហៅថ្នាក់ព្រាពីបុរាណ
គ្មានកិយ៉ាន(១)ឡាក់ហានទឹងរូបអ្វី
ឬថ្នាក់ព្រា ថ្នាក់នេះជាពាក្យថ្មី
បុរាណស្តីថា ថ្នាត់កាំបិតព្រា? ។
នរណាថ្នាត់កាំបិតនៅនេះអេះ
បានជាជាប់នាមនេះដូច្នេះណា
ស័ព្ទកាំបិតយល់លើសយារវាចា
មកសញ្ញាថាតែថ្នាក់ព្រាវិញ ។
ឥបានលោកប្រាជ្ញណាទឹងសួរសាក
ឲ្យដឹងពាក្យថ្នាក់ព្រានេះឯងមិញ
រំពឹងទៅមិនយល់សល់សែនម្និញ

១– ភិយ៉ាគ (សៀម) = គិតគាត ។

កាលណាលោកនឹងចេញកប៉ាល់ទៅ ។
រំខានទុក្ខនឹងមូសរាយាយី
ឯណាទុក្ខនឹងស៊ីម៉ៃមីទៅ(១)
ឯណាទុក្ខនឹងនឹកដល់ឆោមឆៅ
ឯណាទុក្ខនឹងក្តៅចង្អៀតគ្នា ។
នឹកទន្ទឹងបានតិចលេចឡុងបុត
លាបសសុទ្ធអុំអែបមកម្នា
លោកកុម្មីសែរក៏ឡើងកាន់នាវា
រឹងឲ្យស្រាវយុថ្កាចេញវៃ ៗ ។
ខ្ញុំគ្រាន់ស្បើយក្តីមោះព្រោះចង់ធាប់
ច័ក្ររឹងកាប់ទឹកខ្ទាតខ្ទរទាំងព្រៃ
កប៉ាល់គ្រឿនលឿនលើជលាល័យ
បើកអស់ដៃមើលព្រៃប្រប៉ះគ្នា ។
ដល់ព្រែកពកាច់ប្រែបែរឧត្តរ
ក៏រឹងចរតាមបថទីគង្គា
នឹកសង្ស័យព្រែកពនេះមហិមា

១— ម៉ៃមីទៅ (ពាក្យសៀម) = ក្នុងបាយ ។

តាំងនាមាឃើញកើនលើសប្រមាណ ៗ
ពាក្យត្រែកពប្រាប់នាមព្រះពុទ្ធ
មិនគួរគេមុកពុតឈ្មោះភូមិឋាន
ទីនេះសោតពួកនេសាទគេរាប់អាន
តាំងជាស្ថានបាយាប(១)ចាប់ត្រីទេ ៗ
នេះហេតុអីយកនាមព្រះឲ្យឈ្មោះ
មិនគួរសោះទឹងពាក្យអ្នកទន្ទេ
នរណាអេះចាត់នាមនេះមុនគេ
ឬគេគួរព្រោះព្រែកបែកប៉ក្រោះ ៗ
សព្វត្រែកពប្រែជាកពទាំងបី
ព្រះជិនស្រីជាត្រែកពចំពោះ
ព្រោះព្រះអង្គវិសេសគុណពីពេះ
បានជាឈ្មោះព្រះចមត្រែកពការ ៗ
ឯព្រែកនេះពុំឃើញវិសេសអ្វី
វិសេសតែទឹងត្រីជាអាហារ
ពុំគួរតាំងនាមស្មើសាស្តាចារ្យ
ឬហៅដោយពោហារអស្ចារ្យក្រៃ ៗ

១— បាយាប = អារក្សទឹកសម្រាប់អ្នកនេសាទគោរព ។

រំពឹងគិតមិនយល់សត្វត្រៃកត
បង់តែឈប់ទៅមើលទីនោះនៃ
ជាមានអ្វីសាក្សីកណ្ដាលព្រៃ
គួរសង្ស័យទឹងពាក្យត្រៃកតនេះ ៗ
ឬសត្វត្រៃហៅក្រៃលោកតាំងឈ្មោះ
គង់ពីគ្រោះតាមហេតុមានប្អោះប្អេះ
ឬពីដើមព្រះយាងមកនៅនេះ
បានជារិះតាំងហៅត្រៃកតហោង ៗ
ឱលោកណាដឹងការហេតុដើមដាន
សូមមេត្តាប្រោសប្រាណប្រាប់ខ្ញុំផង
ខ្ញុំពីគ្រោះមិនយល់រឹងហ្មួហ្មង
កប៉ាល់ធ្លងកាត់យោគយាងយាវខ្ញី ៗ
លឿនលន្ទឹមតាមបត់យាងយាវត្រង់
កាត់តម្រង់បែរត្រង់ដល់ភូមិថ្មី
ភូមិនោះមានគេនៅជាប្រក្រតី
បត់កំខ្ញីជាប់នាមពាមសីមា ៗ

ឱស្រុកពាមចាត់នាមឈ្មោះពាកេះ
គេបញ្ចុះសីមាពីកាលណា
ត្រើយខាងជើងមានព្រែកបែកជាស្នា
ព្រោះគេថាស្ទឹងនោះទៅទឹកជោរ ។

ឱទឹកជោរទឹកហូរពីភ្នំណា
ធ្លាក់មកពាមសីមាផាសពេញពោរ
ទឹកទន្លេឡើងកល់ទល់មិនហូរ
កាត់ទឹកជោរដល់ព្រាត់វត្តឈើខ្មៅ ។

គន់មើលទៅវត្តលោកលើគោកស្រួល
ជាទីទួលសមជាអារាមនៅ
ឯវត្តនេះយកនាមឈើមកហៅ
នាមឈើខ្មៅលោកណា តាំងនាមនេះ ។

ឬវត្តនេះស្រីខ្មៅចៅធ្វើទេ
យកនាមគេមកតាំងទុកដូច្នេះ
ឬពីដើមមានឈើខ្មៅនៅនេះ
បានជារិះតាំងនាមមកឥឡូវ ។

ពាក្យឈើខ្មៅហៅហាក់នាមខ្មៅបង
ចិត្តចាប់ចងនឹកដល់កែវឆោមឆ្មៅ
ឱព្រះគុណព្រះកែវវត្តឈើខ្មៅ
ខ្ញុំលាទៅនគរវត្តព្រាត់កនិដ្ឋា ។
សូមព្រះគុណប្រោសជួយចក្រពង្ស
ឲ្យស្តេចទ្រង់ចំរើនដោយយសា
ប្រោសប្រាណខ្ញុំឲ្យបានទីឧកញ៉ា
កបសក្តាវុឌ្ឍីស៊ីសុវត្ថិ ។
មែនបើខ្ញុំសម្រេចដូចប្រាថ្នា
ខ្ញុំនឹងគិតហែផ្កាមកថ្វាយថ្វាត់
សូមកុសលព្រះគុណជួយបំបាត់
សព្វទុក្ខរោគខាត់សកលកាយ ។
មួយសូមជ័យជំនះឈ្នះសត្រូវ
ទៅតាមផ្លូវកុំឲ្យមានអន្តរាយ
ទាំងពាលម្រឹគយន់ឃ្នងផងទាំងឡាយ
ជៀសឲ្យឆ្ងាយដោយអំណាចព្រះបមត្រៃ ។
ខ្ញុំសំពះបន់ព្រះវត្តឈើខ្មៅ

កប៉ាល់គ្រឿនលឿនទៅតាមជលស័យ
ត្រូវព្រះពាយរំភើយខ្ញុំទៀយក្រៃ
ក៏លក់តាមសម័យយប់នោះឯង ៗ
លុះបើកដល់មាត់ពីរចេញទន្លេ
កប៉ាល់ររេបើកពុះធ្នូងរាលវែង
រាយោយោកផាត់មករលកផ្សែង
ខ្ញុំបាទឯងក៏ក្រោកចាកដំណេក ៗ
អង្គុយគន់មើលទឹកទន្លេសាប
ឡើងលិចជាបព្រៃព្រឹក្សពន្លឹកពេក
មើលទៅទិសទក្សិណសែនវិវេក
ឃើញតែមេឃម្លូជិតងងឹតឈឹង ៗ
គន់ទៅទិសឧត្តរតេត្លៀសាន
ឃើញជាជានព្រៃវង់វែងរវឹង
មើលទៅទិសបស្ចិមវាលដូចបឹង
ទឹកឡើងនឹងពោរពេញមើលល្ហោះៗ ៗ
កប៉ាល់រឹងច័ក្រដើរស្មើមិនឈប់
រលកខ្ទប់ស្មើរខ្ទាត់ច័ក្រពានពុះ

លោកយោលខ្លោលឡើងដូចគេបោះ
កប៉ាល់ស្ទុះទឹកបែកញែកសាបដះ ៗ
វាយោបោកកប៉ាល់បែរលេលឿន
លោកគ្រឿនច័ក្រគ្រាន់បើកជំនះ
តែកុងកាច់តាមកៀនលោកដះ
កប៉ាល់រះទឹកកាយបែកផ្កាត្រែង ។
មើលទៅទឹកធំពន្លឹកគួរតែខ្លាច
លោមស្វាចលិចព្រៃមើលបែកផ្សែង
ទឹកសង្ស័យទន្លេសាបនេះឯង
លោកណាតែងនាមត្រូវទំនងម៉េះ ៗ
ពាក្យហៅថាទន្លេគេមិនដល់
សព្វនេះយល់មិនត្រូវពាក្យអ្នកបេះ
បាលីទឹកគ្មានតួ "ទ" ទេអេះ
ហៅដលេដូច្នេះទើបបានត្រូវ ៗ
នេះមកហៅទន្លេអក្សរ "ទ"
យក "ទ" ជា "ដ" ប៉ុំម្ដេចក្លូវ

តួ "ន" ជាវគ្គន្តប្រកបនៅ
ស្ដាប់ៗទៅមិនត្រូវពាក្យបាលី ៗ
ឬបុរាណគេហៅ ដលេ ទេ
ដល់ក្រោយយារពាក្យគេកើតពាក្យថ្មី
ទៅជាហៅទន្លេខុសបាលី
ឬសំដីបុរាណហៅយ៉ាងនេះ ៗ
ឬសព្ទនេះជាពាក្យសំស្រ្កឹត
លោកប្រសិទ្ធតួ "ដ" ជា "ទ" អេះ
ធ្វើម្ដេចហ្ន៎បានអ្នកប្រាជ្ញណាចេះ
នឹងសាកសួរសព្ទនេះឲ្យច្បាស់ក៏ ៗ
ឱទន្លេនេះធំមើលបាត់ត្រើយ
លោកណាអើយមកសាងយ៉ាងច្នេះណា
ឬក៏កើតពីបឋមកល្បា
ជាធម្មតាទឹកដីពីបុរាណ ៗ
នឹក ៗ ទៅគួរកោតធម្មជាតិម៉្លេះ
ចេះរិះឲ្យកើតជាភូមិស្ថាន
ជាទន្លេព្រែកស្ទឹងបឹងបួបាន

សម្រាប់ទុកជាស្ថានមច្ឆានៅ ។
ទីខាងលើបេះធ្វើជាទួលគោក
សម្រាប់លោកអាស្រ័យនៅឥតសៅ
តាំងជាភ្នំក្រំថ្មតទៀតទៅ
ជាលំនៅសព្វសត្វម្រឹគបក្សី ។
ទុធម្មជាតិបេះបាត់ជាជាន ៗ
សម្រាប់ទុកជាស្ថានយើងលោកិយ៍
លោកណាអេះបង្កើតអស់ទឹកដី
តាមបាលីថាកើតដោយធម្មតា ។
តែខាងសាសន៍អាព៉ីបន្ទូវជ្វាចាម
គេស្តីតាមតម្រាវោហារថា
ទឹកដីនេះគឺអង្គព្រះអាឡា
យៈហោវ៉ាគេសាងសម្រាប់លោក ។
ខ្ញុំពិគ្រោះមើលតាមគម្ពីរជ្វា
ឃើញខុសគ្នាទឹងហេតុទឹកដីគោក
បើអាឡាសាងមែនគួរអធ្យាគ
ឲ្យត្រូវគ្នាទាំងលោកនោះយល់មែន ។

នេះទឹកដីនិងសព្វសត្វមនុស្សម្នា
ឃើញពីរុធខុសគ្នាទៅទាំងផែន
ឯណាល្អក៏ល្អលើសទាំងផែន
ឯណាសោសោសែន(១)ទាំងភាព ៗ
ដូចដីយើងបាត់ដំបងជាតិដីខ្មៅ
ធ្វើស្រែស្រូវកើតផលតែពល់គ្នា
ស្រុកសៀមរាបម្ដេចដីខ្សាច់មហិមា
ធ្វើចំការស្រែស្រូវមិនសូវផល ៗ
មួយគឺខាងអឺរុបម្ដេចបាត់ល្អ
មនុស្សក៏ចម្រើនធំទាំងសាកល
ខាងឥណ្ឌាមនុស្សខ្មៅៗ ពិកល
ខាងមណ្ឌលយើងម្ដេចមនុស្សតូចទាប ៗ
មួយព្រឹក្សាលតានាមដូចគ្នា
សេនុជាម្ដេចខុសគ្នាវៀងពប

---

១— សោ ភាសាអ្នកស្រុកបាត់ដំបង-សៀមរាប ជាន័យថា: អាក្រក់, គៀយហត់, តំរក់ៗ សោសែន = អាក្រក់ពេកៗ

ទាំងសត្វសោតក៏ខុសអត្តភាព
ខ្លះក៏ទាបខ្លះក៏ខ្ពស់ឃើញខុសគ្នា ។
បើអាឡ្យា សាងមែនម្តេចដូច្នោះ
ខ្ញុំពីគ្រោះមិនសមនឹងផ្កា ថា
វិស័យព្រះនោះប្រៀបដូចបិតា
តោងមេត្តាដល់បុត្រស្មើព្រះទ័យ ។
នេះមកសាងឲ្យកូនមិនស្មើមុខ
ជាអាពុកមនុស្សប្ដុខុសនិស្ស័យ
ស្ដាប់ទៅយល់មិនត្រូវអធ្យាស្រ័យ
ទឹកដីព្រៃក៏កើតដោយធម្មតា ។
ដូចយ៉ាងទឹកទន្លេនិងសមុទ្រ
ឃើញធំផុតទូលាយឆ្ងាយណាសា
ពួកអ្នកឈ្មួញដើរដួញរកភោត្តា
សឹងសែនមហាលំបាកដោយព្យុះខ្យល់ ។
ប្ដុអាឡ្យាតប្ខាពួកអ្នកឈ្មួញ
មិនឲ្យគ្នាដើរដួញក្រោមណ្ឌាល
បានជាមកបង្កើតជាព្យុះខ្យល់

ឲ្យលិចលង់ទូកទ័លទាល់វេទនា ៗ
អើបើយ៉ាងខ្មែរយើងមិនចូលសាសន៍
គួរធ្វើផ្លាស់ទៅចុះក៏ឥតថា
ចុះពួកផ្កាដែលគ្នាខំឧស្សាហ៍
ប្រតិបត្តិសព្វគ្រាតាមមហាម៉ាត់ ៗ
ឯណាយប់គ្នាបួសកាន់ខន្តី
ថ្ងៃឡើងធ្វៀតបង់ត្រីសំឡេះសត្វ
ឯណាគ្នាហ៊ានឲ្យតុកតួនកាត់
ខំប្រតិបត្តិមហាម៉ាត់មិនឲ្យគ្គង ៗ
គួរប្អាល័សះឡើមិនប្រោសប្រាណ
មកក្លែងធ្វើផលបានជកទ្វង
គ្នានាំព្រៃទៅលក់ស្រុកបាត់ដំបង
ឲ្យគ្នាហ្មងធ្វងទៅត្រូវព្យុះខ្យប់ ៗ
បើយើងជាអាល័សះឡើមិនធ្វើបេ្ចះ
ទីត្រង់ណោះគួរធ្វើឲ្យកើតថ្នល់
ឲ្យអ្នកទូកដើរស្រួលមិនតោងវល់

នឹងព្យុះខ្យល់ដូចយ៉ាងអាឡាសាង ។
ទីត្រង់នោះគួរសាងជាកោះធំ
ឲ្យកិរម្យមនុស្សនៅតាំងសង់ខាង
តាំងក្បាលកោះឲ្យកើតជាព្រះប្រាង្គណ៍
មានមាត់បាងចូលចេញឲ្យសប្បាយ ។
នេះអាឡាមកសាងទន្លេសាប
ជាលតែទឹកទៅរាបទូលាយឆ្ងាយ
មនុស្សទៅមកសែនយ៉ាកលំបាកកាយ
ព្រោះអន្តរាយដោយខ្យល់តែរាល់គ្នា ។
អើពួកផ្កាគេថាព្រះគេសាង
នឹងអែបអាងមិនសមនឹងកិរិយា
ពាក្យនេះអញ្ជើញពិចារណា
ជាយកខាងធម្មតាប្អស់លោក ។
ប្អយកខាងព្រះអាឡាដែលថានោះ
សូមពិគ្រោះមើលចុះតាមអធ្យាគ
ឯទឹកដីថ្ងៃខែសម្រាប់លោក

គួរប្រយោគមើលហេតុមើលកិរិយា ៕
កំប៉ាល់ដើរលុះដល់ចុងក្នៀសថ្ងាត់
តែកុងបាត់ចូលបតបោះយុថ្កា
នាំគ្នាដេកសម្រាន្តតាមធម្មតា
អនិច្ចាតែខ្ញុំពុំលក់ឡើយ ៕
ពុលលេកក្នកលើកទឹកដល់ផ្ទះ
កត់មិនឈ្នះគះមិនទឹងព្រលឹងអើយ
ត្រូវមកដេកកប៉ាល់ខ្យល់ក្ហើយ ៗ
ផាត់រំកើយលេកបោកធា ៗ ៕
គន់ទៅខាងឃើញសើន(១)គោមពីរក្លោះ
ភ្លើងភ្លឺប្រុះប្រុង ៗ ក្នុងគង្គា
គោមពីរនោះចេះនៅសព្វវេលា
តាំងជាត្វាប្រាប់ត្វាស្រុកសៀមរាប ៕
ខាងមាត់ពីរក៏តាំងគោមភ្លើងស្ដាំ
អុជប្រចាំចូលចេញទន្លេសាប

---

១— ជិតគោម ឬប៉មខ្ពស់ សម្រាប់យាមល្បាត ។

ខ្ញុំគន់ ៗនឹកកោតលោកជាប
មកលះបាបលោកបុណ្យចេញធនធាន ៗ
ទិញប្រេងអុជគ្រប់ឋានពាមទន្លេ
ទុកឲ្យគេអ្នកដើរក្នុងជលឋាន
ដល់ពេលយប់នឹងដឹងទីដែនដាន
ចេញចូលបានឥតមានក្តីបែងវែង ៗ
គោមនោះសោតនេះនៅជាប្រក្រតី
ដល់រាត្រីទើបឃើញភ្លើងភ្លឺចែង
ដល់ពេលថ្ងៃពុំយល់ព្រោះសូរ្យសែង
គេចាត់ចែងថែមប្រេងដប់ថ្ងៃម្តង ៗ
ខ្ញុំយល់ ៗ សរសើរលោកបារាំង
លោកមកតាំងអុជគោមភ្លឺកន្លង
ប្រាថ្នាទុកជាទានឲ្យអ្នកផង
បានដើរថ្លងឃើញភ្លើងជាសញ្ញា ៗ
ឥស្រុកខ្មែរតាំងតែពីនេះទៅ
មានតែសុខឥតសៅឥតទុក្ខា

បានបារាំងលោកតាំងគ្រង់រក្សា
តែងសីមាកម្ពុជាឲ្យពណ្ណរាយ ៗ
តែត្រឹមទីទន្លេជាស្ពានស្វាត់
មករេះបាត់អុជភ្លើងប្រចាំហ្នាយ
រាស្ត្រទៅមករកតាមស្រុកឆ្ងាយ ៗ
ដើរសប្បាយមិនគោងវង្វេងផ្លូវ ៗ
ឱទន្លេតាំងតែពីបុរាណ
មិនដែលមាននរណាបំភ្លឺទៅ
ឥឡូវនេះមកបានបារាំងនៅ
ឲ្យអុជគោមធ្លូទៅទាំងគង្គា ៗ
សែនរុងរឿងថ្កើងហើយទន្លេសាប
ពីនេះទៅដរាបឥតក័យា
ឱរាត្រីយប់នេះជួនវេលា
ខ្ញុំនិទ្រាពុំលក់ជាទុក្ខក្រៃ ៗ
បែរទៅទិសបូព៌ាឃើញរស្មី
ព្រះឆ្យើអរុណរះសែនថ្លៃ

ពួកកប៉ាល់ក៏ភ្ញាក់ឡើងទីទៃ
ស្រាវយុថ្កាវ៉ាៗ ថយម្នីម្នា ៗ
កប៉ាល់គ្រឿនលឿនចូលទៅតាមព្រែក
ណាចង្អៀតក៏ជ្រែកបែកជាផ្លា
តែកុងកាច់បត់តាមទីគង្គា
មើលព្រឹក្សាដុះហែតាមក្បែរផ្លូវ ៗ
ខ្លះដើមខ្ពស់លូតលាស់ខ្នងលំពង់
ខ្លះទាបទឹកលិចពុងឃើញខ្មៅ ៗ
គោតហ៊្នុំឈើរនាមធន់ណាស់ទៅ
ទឹកលិចនៅប្រាំខែប្រែមិនក្ស័យ ៗ
នព្រៃអើយព្រៃដុះជារនាម
ខ្លះជាពាមស្បាតជិតបិទសែងថ្ងៃ
ខ្លះខ្ពស់ស្រោងផុតទឹកពន្ទឹកក្រៃ
សត្វអាស្រ័យជាស្ថានសម្រាន្តនៅ ៗ
កប៉ាល់បើកលុះដល់កន្លាយគម
ឃើញភ្នំក្រោមនៅខាងឯលិចផ្លូវ
នភ្នំក្រោមតូចល្មមមាននុស្សនៅ

មើល ៗ ទៅពុំឃើញមានដើមឈើ ៗ
ជាភ្នំដិលត្រងិលមានតែស្មៅ
មានដើមពោធិមួយនៅកំពូលលើ
ក្រោយពោធិមានវិហារគេទើបធ្វើ
វត្តនោះតើលោកណាសទ្ធាសាង ៗ
ឯក្រោយធ្លាវិហារមានប្រាសាទ
វិចិត្រស្អាតដោយថ្មកជាប្រាង្គ
ជារបស់បុរាណលោកសំអាង
ទំនង យ៉ាងបញ្ចុះព្រះធាតុក្សត្រ ៗ
ឬជាទីតម្កល់ព្រះបដិមា
សម្រាប់អ្នកសាសនាឡើងប្រណិបតន៍
ទប្រាង្គនេះលោកណាមកចែងចាត់
មាននៅស្ពានបង្ហាត់ខឿនខ្វាត់ខ្វែង ៗ
ឥឡូវនេះដំរុតទ្រុឌទ្រោមធ្លាយ
ថ្មរុះពាយតាមជាយជើងកំពែង
ស្តាយអើយស្តាយប្រាសាទប្រសើរស្តែង
បានលោកណាចាត់ចែងជួសជាថ្មី ៗ

មើលប្រាសាទលើភ្នំស្ទើរយំស្តាយ
មិនគួរមកអន្តរាយខ្ចាយដោយដី
ស្តាយតែស្នាដៃធ្វើស្មើកោសី
មិនគួរបីបែកបាក់ធ្លាក់ធ្លាយធ្លុះ ៗ
ខាងជើងភ្នំមានវត្តលោកសង្ឃនៅ
មានផ្លូវឡើងទៅខាងវត្តនោះ
ឱភ្នំនេះស្តាប់ទៅយល់ពិរោះ
សញ្ញាឈ្មោះភ្នំក្រោមល្មមមានអាង ៗ
ព្រោះភ្នំគេសឹងតែនៅខាងលើ
មានដើមឈើដុះលើឃើញច្រូងច្រាង
ភ្នំមួយនេះមកតាំងនៅក្នុងបាង
មានទីអាងយ៉ាងនេះជាសាក្សី ៗ
បានជាហៅភ្នំក្រោមព្រោះក្រោមគេ
នៅខាងជាយទន្លេអ្នកធ្វើត្រី
ឥឡូវមានអ្នកស្រុកនៅប្រក្រតី
ដាំឫស្សីដូងស្វាចំការបេក ៗ
ឱភ្នំនេះជាទីពីបុរាណ

សមជាស្ថានសំណាក់អ្នកវិវេក
និកសរសើរប្រាសាទប្រសើរពេក
ខ្ញុំក្រឡេកមើលទៅទិឧត្តក ៗ
ឃើញទីនាំងតាំងបតនៅវៀងភយ
ប្រចាំទ្វីបម្ករក្លាយកៈសាយណា
ទូកតែហោរីវីតម្លួងភាពផាយមា(១)
ក៏ដឹងថាព្រះទីនាំងព្រះចក្រី ៗ
ហៅភ្នាក់ងារត្រួតត្រាព្រះទីនាំង
ឲ្យបតតាំងតាមថៃវចុងព្រែកថ្មី
ទូកកាជវង្សបតក្នុងទូកកុងវ៉យ
ក្រុមមន្ត្រីបតអមលោមក្រៅថ្លា ៗ
ទូកអស់នេះទ្រង់ឲ្យមកប្រហំ
មុនទម្រាំព្រះបរមរាជា
ដល់ដប់កើតថ្ងៃសុក្រស្ដេចលីលា
យាន៍ដោយកជនាវាកប៉ាល់ធំ ៗ

---

១— ភាពសេះផាយ គឺទូកទីនាំងអង្គ ៗ

លុះកប៉ាល់ពជការស្រុកព្រះដំបង
ទៅដល់ដងពលវែងជាចុងកុម(១)
លោកឲ្យបោះយុថ្កាចតប្រជុំ
អ្នកជំទុំនាំគ្នាមើលត្រៀបត្រា ។
លុះកប៉ាល់ចតស្រេចលេចទូកបី
ក្រុមមន្ត្រីសៀមពបទីឧកញ៉ា
មកទទួលលោកជំជាឥស្សរ
ជីគេបកកាសាថែងការផង ។
លោកកុម្មិសែរអធ្យាស្រ័យតាមហេតុ
បាត់ឲ្យលោកទៅហ្វាយខែត្រព្រះដំបង
នៅកប៉ាល់ឯក្រោយចាំព៉ប់រង
ទទួលអង្គច្បាស់ច្បងស្តេចយាត្រា ។
តែខ្លួនលោកនឹងលោកសង្ឃបីអង្គ
ពុំកវង់បុះទូកអ្នកឧកញ៉ា
ខ្ញុំបាទឯងជាបាវលោកមេត្តា
ឲ្យយាត្រាទៅមុនដោយកំសាន្ត ។

១ – តាមត្រូវគឺបុគ្គភូមិ តែនេះតម្រូវតាមសម្ផស្សកាព្យ ។

ទើបផ្ញួនហិបពូកដាក់ទូកស្រេច
មួយរំពេចក៏ចេញតាមផលស្ថាន
ពួកកំណែនគេណ្ហាចែវខំចែវប្រាន
កាត់ត្រង់ផានទំជ្រទឹកព្រែកជីកថ្មី ៗ
ចែវអែបរ៉ែបអបខាងព្រះទីនាំង
ខ្ញុំក៏តាំងលួចគន់មើលស្រីៗ
ពួកអ្នកក្នុងតែងអង្គល្អប្រិមប្រិយ៍
ធើក៏គ្រហាក់ស្រីទេពកញ្ញា ៗ
សឹងប្រដាប់សង្វារចារុំខ្សែដៃ
ទំហ៊ូថ្លៃវិចិត្ររចនា
ទទឹមពេជ្រលេចសែងព្រះសុរិយា
សូរ្យកាន្តកែវកាញ្ចនាប៉ព្រោតព្រោយ ៗ
ស្ទៀកខៀនខាត់តែអេវខាំម៉ាស៊ុ(១)
ផាត់ធីគន្ធរសពិដោរសាយ
ខ្លះតែងតួស្កុភាពភាពសៀមក្លាយ

---

១– ខាំម៉ាស៊ុ = ក្រម៉ាស៊ី គឺក្រមាពណ៌ ។

ខ្លះតែងកាយអាវសាយក្លាយបាំង ។
ពួកសាវឡឹកងូតទឹកប្រឡែងគ្នា
សើចហោហាហៃហលខាងព្រះទីនាំង
ខ្លះមិនខ្លាចអំណាចពួកក្រុមវាំង
ក៏សើចខ្លាំងលើសគេរវៃតែខ្លួន ។
ខ្លះអង្គុយស៊ិយសក់កញ្ចាក់ខាង
ខ្លះសំអាងសមសក្តិហាក់ទឹមនួន
តែងប្រកួតអួតអង្គទ្រង់ដោយខ្លួន
មើលសមស្លូនសមសក្តិព្រះចក្រា ។
ខ្ញុំគន់ៗ សរសើរព្រះបារមី
ព្រះចក្រីជាត្បូងលើកេសា
កបនារីស្អាតៗ បាទបរិចា(១)
សែនមហាចំរើនព្រះកិត្តិយស ។
គន់ទៅចូកពួកសេវកាមាត្យ
សឹងស្អាត ៗ រុងរឿងដោយគ្រឿងខ្ពស់
តែងប្រកួតអួតគ្នាតាមសក្តិយស

១– ក្លាយពី បាទបរិចារិកា = ស្ត្រីអ្នកបម្រើជិតជើង។

បំរុងតាមកាមសរវេណីក្សត្រ ៗ
សរសើរទូកខុនណាងនូវនាងអ្នក
ខ្ញុំតែងដាក់និពសនេះខាត់ៗ (១)
ពុំពិស្ដារវិត្ដារឲ្យច្រើនអត្ដ
ព្រោះក្ដីខាត់ពុំស្គាល់អ្នកក្នុំពេញ ៗ
បានជាតែងសង្ខេបបែបខ្លី ៗ
តាមសេចក្ដីយល់ខ្លះមិនប្ញាស់មិញ
បើខ្ញុំស្គាល់ឈ្មោះលោកអ្នកក្នុំពេញ
ទឹងតែងចេញឈ្មោះលោកឲ្យគ្រប់គ្នា ៗ
សូមទានទោសកុំខឹងខ្ញុំអ្នកតែង
មិនសម្ដែងឈ្មោះលោកចូលផងណា
ត្បិតខ្ញុំអ្នកព្រះដំបងក្រៅសមា
ហេតុដូច្នោះបានជាតែងកាត់ខ្លី ៗ
ពួកកំណែនបែបស្រុតតាមព្រែកដឹក
សែនវិវេតមើលព្រែកគេដឹកថ្មី
ទឹកកឹកកក់ហូរចាក់ធ្លាក់អាចម៍ដី

---

១. ខាត់ៗ = កាត់ៗ សង្ខេបៗ ។

ថែវទៅដល់ភូមិថ្មីឫស្សីព្រលក ។
ឃើញអ្នកស្រុកតែងធ្លាមាគ្គាល័យ
ដោតទង់ជ័យកាយរៀងតាមមាត់ព្រែក
ខ្វះតែគូប្រទូប៉ាប្រដាប់ដក(១)
ពោះកំប៉ុងពែងបកអុចសំអាង ។
គន់អ្នកស្រុកសៀមរាបសុភាពគួរ
នៅជាជួរដងស្ទឹងទាំងសងខាង
ស្ទឹងក៏តូចប្រាំងក៏ទាបជាភាពបាង
ទទឹងយ៉ាងបីព្យាមថ្នាយប្រាកដ ។
រយៈផ្លូវទៅពីចុងភ្លៀសឯង
ដល់កំពែងសៀមរាបលោកកំណត់
បានបីរយកៅសិបប្រាំសិនគត់
លោកវាស់ទុកជាបទថែបលាយថែង ។
តែខ្ញុំពេញបាកទឹកន្ទាយគម
ថ្ងៃទៀបត្រង់ក៏ល្មមដល់កំពែង

១. ប្រទូប៉ា = ស៊ុមស្នឹកឈើស្រស់ ។ ប្រដាប់ដក = ប្រដាប់ទៅដោយផ្កា ។

ថែវចូលចតអែបស្ពានភ្នាក់ងារតែង
ត្រង់កន្លែងសានខ្វែងត្រើយខាងលិច ៗ
ពួកបាវបោយកូនក្មួយជួយគ្នារើ
ទ្រព្យរបស់ដាក់លើគោករំពេច
ខ្លះក៏មានតែទែនិងបង្វេច
ក៏ស្ពាយគេចឡើងគោកជ្រកគ្រឹហា ៗ
បោយបាំងតាំងរៀបគ្រឿងលើគោក
ចាំមើលលោកនៅទីខាងផ្លូវថ្លា
រង់រេះកំណែននឹងលីលា
ឡើងទៅនាប្រាសាទនគរវត្ត ៗ
លោកឧកញ៉ាស្មៀនត្រាសទ្ធាបុណ្យ
មកនិមន្តលោកសង្ឃទៅផ្ទះគាត់
ចាត់ចង្ហាន់ប្រគេនតាមកិច្ចវត្ត
សម្រេចកត្តនៅផ្ទះលោកស្មៀនត្រា ៗ
ឯខ្ញុំបាទនាំកៀនទៅផ្សារត្រី
ទិញចំណីអាស្រ័យតាមធម្មតា

ស្បូរបេកិច្ចនាំគ្នាចរយាត្រា
មកចាំលោកនៅនាមុខកំពែង ៗ
គន់មើលគ្រឹះស្ថានចៅហ្វាយស្រុក
សែនជាសុខសមសក្តិហាក់គួរស្ញែង
តាំងគ្រឹហា នៅនាក្រៅកំពែង
រៀបចាត់ចែងតែងការទទួលស្ដេច ៗ
ដោតទង់ជ័យបីជាន់ជាជួរជុំ
ប្រកបគុំបុប្ផាផ្ការំលេច
កែមស្ទឹកឃើធ្វើស៊ុមប្រទូពេជ្រ
រៀបជាល្បាច់វល្លិ៍វណ្ណពន្ធពេនពាក់ ៗ
មានសៀរ័កស៊ីប៉ាល់ចាំងសែស
នាយប្រទេសចាត់ការទាហានសក្តិ
យកកំពែងសៀមរាបជាសំណាក់
តាំងពិភ័ក្តិរក្សាការសត្រូវ ៗ
ខ្ញុំគន់មើលកំពែងវែងវើង
ស្ងាត់ត្រៃឈឹងពុំមាននរណានៅ

ព្រៃដុះជិតស្បាតជិតទាំងក្នុងក្រៅ
សែនហ្មងសៅមើលទៅគួរតែស្តាយ ៗ
ប៉មជម្រុតទ្វារទ្រុឌធ្លាក់ទីទៃ
ពួរពោធិជ្រៃជ្រៀតបាក់បាក់ធ្លុះធ្លាយ
លោកបាពំងតាំងឲ្យរើទំលាយ
យកទៅវាយបំបាក់បាក់ផ្លូវធ្លា ៗ
ទុកកំពែងគេតែងដោយថ្មក្រៀម
ស្នាដៃសៀមគេធ្វើកាលយុទ្ធនា
ស្រុកខ្មែរយើងនឹងយួនកើតច្បាំងគ្នា
សៀមជានាក់ប៉ះរងសង្គ្រាមយួន ៗ
លោកចៅឃុនបឌិននាយបង្គាប់
ជាមេទ័ពលើកចេញមកតាមក្បួន
ទើបឲ្យកកំពែងប៉មមាំមួន
ចាត់ជាក្បួនបន្ទាយការសត្រូវ ៗ
តាំងមកដល់ពជ្យលោកអគ្គវែយម
លោកសមសែមចាត់ចែងតែងតាំងនៅ

កាលណោះឯងកំពែងសុខឥតសៅ
ដល់ឥឡូវត្រូវដែរពដការថ្មី ។
លោកឲ្យរើទៅរាយដាក់ផ្លូវថ្លា
សម្រាប់ឲ្យមនុស្សម្នាដើរប្រក្រតី
ខ្ញុំគិត ៗ អនិច្ចំទាំងបូរី
តែទឹកដីគង់ដល់ផ្លូវអនិច្ចា ។
ទស្រុកសៀមពបជាភាពចាស់
សឹងខ្សាច់ដាសមិនថាទីត្រង់ណា
អ្នកនឹងរកប្រយោជន៍ស្រែចំការ
នឹងបានផលប៉ុនណារក្សាកាយ ។
មួយសង្ស័យនឹងស្រុកសៀមពបនេះ
បុពណារះឲ្យឈ្មោះខុសបរិយាយ
ស្រុកខ្មែរទេម្ដេចគេយកសៀមលាយ
តាមបរិយាយសាវតារតម្រាមាន ។
កាលព្រះចមចក្រីត្រីនេត្រក្សត្រ
គ្រងសម្បត្តិឥន្ទប័តបូរីស្ថាន

គឺនគរធំនៅជាប្រធាន
ចមក្សត្រក្សាន្តមានបុណ្យលើសនានា ៗ
មានព្រះនេត្របីភ្លែកប្លែកជាងជន
នេត្រកណ្ដាលតែគន់មើលនរណា
អ្នកនោះឯងក៏ដល់ក្ស័យជីវ៉ា
ពួកកាពក៏ស្វែងក្រែងបារមី ៗ
លុះណាងស្នោគឺសៀមជាសួយទឹក
កជាសឹកលើកមកវាយបូរី
ដល់មកទីត្រង់នេះបោះយោធី
តាំងជាទីសមរភូមិជ័យ ៗ
គ្រាន់ជ្រាបដល់ព្រះនរិន្ទ្រពិនក្រស័ត្រ
ចមឥន្ទប័តក៏ទ្រង់ព្រះក្រោធក្រៃ
ទើបលើកពួកចតុរង្គក្នុងវៀងជ័យ
ចេញតដៃតែរឹទ្ធីបាន ៗ
មកដល់ស្រេចស្ដេចបើកព្រះនេត្រកែវ
តែមួយប្លែវត្រូវសៀមស្លៀមមិនបាន
ពោលអាវុធចាកដៃលុតក្រាបក្រាន

កបពុំហ៊ានតឫទ្ធិតវិញទៅ ៗ
ហេតុដូច្នោះបានហៅ ថាសៀមកប
ព្រោះមានភាពសៀមខ្លាចព្រះចមហៅ
បុកណាភជបារឹកតាំងនាមនៅ
ដល់ឥឡូវសៀមប្រែហៅសៀមក៉ត ៗ
ពាក្យសៀមក៉តប្រែថាសៀមឥតក្រែង
តាំងសំដែងឥទ្ធិឫទ្ធិគិតប្រមាទ
ដើរទន្ទ្រានរានរុកសីហនាទ
មិនក្រែងជាតិកម្ពុជាវេលានោះ ៗ
ព្រោះស្រុកនេះជាស្រុកឡើងសៈយ៉ាម
សៀមធ្វើតាមអំណាចឥតខ្លាចសោះ
ពាក្យ "ក៉ត" សព្វនេះប្រែដូច្នោះ
បើកផ្លះវិញនោះថាដែនស្រុក ៗ
ទំនងយ៉ាងសៀមប្រើ "ផ្ល" ជាខ្យល់
ប្រយោគដល់តួ "ត" តាំងជាមុខ
ខ្ញុំពីគ្រោះសព្វក៉តឱបាតទុក
ឥឡូវស្រុកបានមកខ្មែរវិញហើយ ៗ

គឺបានដោយអំណាចកជនិវេសន៍
ក្រុងបារិសយើងតាំងជាកោះកើយ
សៀមបាងកកលូកមកមិនបានឡើយ
យើងបង្ហើយ សៀមក៉ត ហៅ សៀមរត់ ៗ
ព្រោះកាលសៀមប្រគល់ទឹកដីឲ្យ
ត្រឡប់ក្រោយវិលទៅបាងកកហ្មត់
ហេតុនោះគួរពួកយើងបោះប្រាកដ
សន្ទះហៅស្រុក សៀមរត់ វិញ ៗ
ពណ៌នាសៀមកបគាបសៀមក៉ត
សែនអនាថនឹកឡើងគួរតែម្ចេញ
ព្រោះពីដើមចុះយួនជួនសៀមវិញ
ឥឡូវពេញដូចមុនគុណបារិស ៗ
អើស្រុកខ្មែរកែមុខបានសុខសាន្ត
ព្រោះរួមស្ថានក្នុំពេញកជនិវេសន៍
កិត្តិយសសុសសាយទូប្រទេស
បារាំងសែសវិសេសជាបិតា ៗ
មួយដូចយ៉ាងប្រាសាទនគរវត្ត

LIBRARY BUDDHIST INSTITUTE

ពុកណាក្ស័ត្របាត់សានក្នុងសេមា
យូរអង្វែងពុំបែងផាកផ្សណា
ទៅជាព្រៃព្រឹក្សាស្ងាត់នៅ ៗ
ពុំមានលោកឯណាជួសជុលបាន
បោលជាស្ថានសមសាន្តសែនហ្មងសៅ
ដល់ឥឡូវបានលោកបារាំងនៅ
លោកបាត់ផ្លូវជួសជុលវិបុលា(១) ៗ

ពណ៌នាបន្តិចលេបរទេះ

ព្រមទាំងសេះជំនិះលោកឥស្សរ
បរមកដល់របល់ចូលមីម្មា
ខ្ញុំនាំគ្នាផ្ទុករបស់ហើយបរទៅ ៗ
លោកកុម្មីសែរដិះសេះបរទៅមុខ
ពួកអ្នកស្រុកនាំគ្នាមើលខ្វលខ្វៅ
ពួកខ្ញុំបាចដើរឃុំរទេះទៅ
បរតាមផ្លូវខ្សែល្អួសលោកជួសថ្មី ៗ
ព្រះទិនករបរវៃអរុណរៃង

---

១ · វិបុល = ក្រៃលែង, បរិបូរ ។

កំដៅសែងព្រះអាទិត្យរឹទ្ធិរង្សី
ពួកអ្នកដើរសែនក្តៅសៅធរី
ញ័រឥន្ទ្រិយញើសស្រោកប្រឡាក់កាយ ។
អនិច្ចាតែខ្ញុំគ្មានឆ័ត្របាំង
ត្រូវកំឡាំងព្រះអាទិត្យតែក្រហាយ
ឯណាទុក្ខនឹងនឹកដល់ឆោមឆាយ
សេចក្តីហ្វាយឆ្ងាយមាសនិរាសមក ។
ស្តាយអើយស្តាយកាយកែវកនិដ្ឋា
មកផងក៏នឹងនាំមើលប្រកល្ហក
ទុរេដើមពោគជួបពោគពាគរឹតរក
ទៅដើមផ្លូកមិនធ្លាប់មកឯកា ។
គន់ព្រឹក្សាលតាដុះដោយព្រៃ
ខ្លះល្ហុតលៃលំពន់ទ្រន់ផ្លែផ្កា
សកុណជាតិហើរចាប់ចុងសាខា
បឹកផលាសត្វស៊ានអនេកក្រៃ ។
ភមរីហើរត្រង់កន្ទន់ចរ
ត្រឹបកេសរបុប្ផាពនាល័យ

សត្វហ្វីង ៗ ទ្រហឹងកណ្ដាលព្រៃ
ប្រឡំសត្វពពែបន្ទឺសៀង ។
សែនស្រណោះសត្វសោកវិវេកចិត្ត
ទុំប្រជិតសារិកាជាគូគៀង
កោកិលោ(១)លោតលេងទំរៀង
បញ្ចោញសៀងក្ងាំងក្រាងក្រអៅ(២) ។
គន់ចំបក់ដូចបងចំបែងចិត្ត
ចៅដើមខ្វិតដូចបងមកខ្វែងចៅ
ឱដើមសោកដូចបងមកសោកសៅ
ដើមស្រឡៅនៅស្រឡាញ់ចេញចោលមក ។
ឱដើមថ្កាន់គេធ្លាប់លាបដំពៅ
ដើមស្រឡៅធ្វើបែវគួរកាប់យក
ធ្លកអើយធ្លកមិនធ្លាក់ផ្លែចុះមក
ខ្ញុំនឹងយកធ្វើប៉ុយបង្ហុយពោះ ។
គន់ដើមយាងកងយោរយោកដោយខ្យល់
គេកាប់ដុតយកជ័រធ្វើចន្លុះ
អទិច្ចាដើមយាងម្ដេចយ៉ាងនោះ

---

១— ចេះត្វាតាភើ ។ ២— លាស់ត្រូវរំពេក ។

ឲ្យគេបោះទាំងស្រស់ផុតផូរច្នេះ ៗ
យានអើយយានទៅសាងកម្មយ៉ាងណា
បានជាមកវេទនាឲ្យក្ញើងចេះ
ឈើឯទៀតមិនដូចឈើយាននេះ
បើតាមរិះឈើនេះចុះតម្រា ៗ
សមណៈមានទ្រព្យសិកាកួន
ស្រីមានខ្លួនប្រុសកួនដោយកាមា
ព្រឹក្សាជាតិយ៉ាប់យ៉ឺនព្រោះផ្លែផ្កា
ត្រីអាំងមានទើបឆ្នាមកយាយី ៗ
យានឯងយ៉ាប់ព្រោះមានជ័រទឹកទៅ
បានជាត្រូវកំដៅព្រះអគ្គី
ឈើឯទៀតឥតជ័រគេរុឡ្យី
គ្មាននរណាយាយីដូចយានឯង ៗ
ទព្រឹក្សាត្រូវការមិនថាអ្វី
កើតសម្រាប់ផែនដីប្រាកដស្ដែង
ដូចរូបកាយសត្វាគេតុបតែង
មិនផុតការគ្នាឯងតែងអាស្រ័យ ៗ

ឧព្រឹក្យាលតានាមថ្ងៃក ១
បុកណាចែកបេះឲ្យឈ្មោះទីទៃ
កោតហ្នុំលោកបុកណាបេះកែខៃ
ឲ្យនាមសត្វឈើព្រៃគ្រាន់កំណត់ ។
រយៈផ្លូវទៅពីសៀមពបឯង
ដល់កន្ទេងមុខនាគនគរវត្ត
បានមួយរយសែសិបសិនទៀងទាត់
សេសប្រាំសិនសន្ធតកត់មាត្រា ។
លុះដើរដល់ជ្រៃធំត្រសុមម្ទប់
បបួលគ្នាចូលឈប់ម្ទប់សាខា
សម្រាកញើសរំហើយដោយវាតា
ព្រះសុរិយោជ្រេសែនឱនោទ័យ ។
ទើបនាំគ្នាបរលើបាកទីនោះ
ក័ក្រ្តាផ្តោះតម្រង់ត្រង់ដល់ព្វ
មន្ទីរថ្មីលោកតាំងជារំងជ័យ
សម្រាប់ទីក្សត្រថ្ងៃព្រះទ្រង់សក្តិ ។
លោកសក្តិបីស្តីទីព្រះគាថ្ង

ជាឥស្សរក្នុងការព្រះដំណាក់
ទៅហ្វាយខែត្រសៀមរាបបំរុងសក្តិ
ទទួលភ្នាក់ងារគេណ្ឌាពស្រ្តតែងផ្លូវ ។
ទៅហ្វាយខែត្រព្រះដំបងរ៉ាប់(១)សំអាង
គេណ្ឌាពួកជាងរចនាការក្នុងក្រៅ
ទៅហ្វាយស្រុកគ្រប់ខែត្រគ្រប់លំនៅ
សឹងចុះត្រូវកំណែនការទទៃ ។
គឺឧកញ៉ាស្វាយបេកចំណែកមុខ
និងឧកញ៉ាភ្នំស្រុក ខែត្រដើងព្រៃ
រួមឧកញ៉ាសួរសក្តិសោភ័ណក្រៃ
ត្រូវធ្វើតម្វាជ័យដំណាក់ធំ ។
គេណ្ឌាឧកញ៉ាក្រឡាញ់បញ្ចូលមុខ
រួមឧកញ៉ាខែត្រស្រុកសូទ្រនិគម
ត្រូវពងខោលពងសែក(២)បែកតាមមុម
ឯពងថែវអមជុំត្រូវកម្ទី ។

---

១— រ៉ាប់ = ធានា, រ៉ាប់រង, ទទួលបន្ទុក ។ ២— ពងខោល = ពងល្ពៅ ឬពងលេងយ៉ាំផ្សេង ៗ ។ ពងសែក = សំណាក់ដែលមានទឹកព្រាត់ទឹកលប់ណាគមុខជាដើម ។

គឺស្រុកពួកស្រុកមោងស្រុកត្នោតផង
ទាំងទឹកជោរបាត់ដំបងមង្គលបូរី
ឯឧកញ៉ាមង្គលធរនិន្ទថ្មី
ត្រូវបើកត្រីអង្ករបែកគ្រប់កង ៗ
ទៅហ្វាយខែត្រសៀមរាបនាយកំណែន
ឲ្យកោះកេណ្ឌរទេះដាងរយហោង
កេណ្ឌទូកធំសាមសិបមាននាយកង
ចាំកប់រង់ចូលចេញខាងជើងទឹក ៗ
កេណ្ឌគូលីមួយរយប្រចាំនៅ
តែការដល់គេហៅចុះបែរត្រឹក
កស្ត្រសៀមរាបរវល់ខ្វល់ពន្ទឹក
ទាំងជើងគោកជើងទឹកចេញគ្រប់ដាន ៗ
ខាងការរហ័សកេណ្ឌសេះហាសិបប្អាយ
សម្រាប់នាយ ៗ ដើរពុំបាន
តាំងរថាសារថីព្រះកជយាន
ប្រចាំក៏ប៉ក្សត្រក្សត្តន្តស្តេចយាងដល់ ៗ

ពួកក្រុមការបាត់ការព្រះពន្លា
សឹងប្រកួតអួតគ្នាគ្រប់មណ្ឌល
ជ្រើសតែជាងស្ទាត់ ៗ ហត្ថកោសល្យ
ធ្វើមិនធ្លល់ក្នុងការដំណាក់ថ្មី ៗ
ឯរោងលោកកុម្មីសែរតាំងខាងស្ពាន
មានទាហានតាំងរានចាំប្រក្រតី
បន្ទាប់តរោងផ្ដុំក្រុមមន្ត្រី
កណ្ដាលលោកសក្តិបីរាជអាជ្ញា ៗ
ចុងខាងត្បូងគឺរោងលោកចៅហ្វាយ
ព្រះដំបងតាំងរាយប្រជិតគ្នា
លោកសក្តិបីនាយត្រួតលើព្រះពញា
ឲ្យកេណ្ឌតាមយសាបណ្ដាសក្តិ ៗ
សឹងប្រដាប់ឈើស្រស់របស់ព្រៃ
ក្រងជាកួងមាលៃបំពេនពាក់
បងសំយុងជាកួងរៀបថ្នាក់
កែមបម្លាក់មើលបម្លែកក្អែកលោកិយ៍ ៗ
ឯពួកចិនតែងខាងហាងដាក់ផ្សារ

មានទំនិញសព្វប្រការគ្មានខ្វះអ្វី
ខ្លះតាំងពានលក់ភោជន៍ក័ស្តុចំណី
ស្លា បារី កាហ្វេ តែ នំប៉័ង ។
ខាងពួកខ្មែរអ្នកស្រុកលក់ចេកស្ងោរ
នំបាក់កោរនំផាលទូវនំបាំង
ខ្លះក៏លក់នំបញ្ចុកលតបាយអាំង
ខ្លះក៏តាំងពានមី ពានសុព ។
បណ្តាពួកអ្នកទៅនគរវត្ត
ពុំមានអត់ទឹងស្បៀងលៀងដីរ៉
មានតែប្រាក់ក៏ទិញបានភោក្តា
សែនមហាលោះលាយសប្បាយក្រៃ ។
ដោយទីនោះធ្លាក់ទៅជាសមសាន
លោកមករៀបជាស្ថានព្រះរាំងជ័យ
មើលសព្រោតក្លីជ្រះជាសទាំងព្រៃ
ហាក់មឿងមានក្សត្រថ្លៃគង់ប្រក្រតី ។
ឯខាងពួកបាកំង តាំង សាងតឹក ១)

---

១ — គ្រឹះស្ថានសំខាន់ៗ (ពាក្យប្រើតាមសៀម) ។

មើលភីលឹក(១)ប្រក់សឹងស័ក្តិសី
ដញ្ឈាំងលា បបាយអពណ៌លឿងខ្ចី
គ្រឹះពីដីផ្ទៃស្មើល្អបវរ ៗ
ផ្ទះនោះឯងវែងរ៉ាប់ទីប្រជុំ
លោកគូវៃណើរជាធំព្រៃនគរ
លោកអញ្ជើញមកដោយក្តីសាទរ
សមោសរពជគារនគរវត្ត ៗ
ខ្ញុំបាទយល់ទីស្ថានលោកតែងថ្មី
នឹកសរសើរបារមីព្រះចមក្សត្រ
គ្រាន់តែយាងមួយគ្រាក៏កើតចាត់
ទីព្រៃស្ងាត់ក្លាយកើតជាវាំងស្ថាន ៗ
ឱព្រះគុណប្រកបដោយបុណ្យក្រៃ
លើសនិស្ស័យយើងពុំប្រមាណបាន
ខំឧស្សាហ៍យាងមកទីបុរាណ
ឲ្យព្រៃប្រែជាស្ថានបូរីរតន៍ ៗ

---

១. ភីលឹក = ប្លែក, គួរឲ្យឆ្ងល់ ។

មើលកសិណ(១)យល់ក្រសែដលេសាយ(២)
វាលវែងឆ្ងាយឧបអមនគរវត្ត
លោកជីកធ្វើជាគូរាំងស្ដាតស្ដាត់
មានបង្ហាត់ខឿនខណ្ឌខាត់តៃរី(៣) ។

គន់គង្គាក្រសិន្ធុវែងវែង
ខឿនសុទ្ធសឹងថ្មជាជាសនាទី
ឆ្លាក់ជារូបក្បាច់ហូតហៀនពដីរ
ជណ្ដើរកាច់ក្បាច់ភ្ញីដកបន្ទន់ថែង ។

កណ្ដាលហាំនមានស្ពានថ្មជាជាស
បំនួនក្រាស់ជាងសិនសែនគួរស្ញើង
តែកំណត់ទទឹងនឹងប្រវែង
មានក្ទុងក្បូនលាយថែងលោះកបែងទុក ។

ខាងចុងស្ពានមានឆ្លាជាប់ផ្លូវ

---

១— កសិណ = គូទឹក, ស្រះដែលជីកធ្វើជាកំពែងជា
គោលបារឹក   ២— ប្រឡាយទឹកយ៉ាងវែងអន្លាយ ។
៣— ខាត់តៃរី = ការពារសត្រូវ ។ កាត់សត្រូវ ។

មានរូបតោឈរនៅគ្រប់មុមមុខ
តោសិលាខ្លះនៅពុំទាន់ពុក
ខ្លះបែកមុខបាក់ក្រញាំពិការកាយ ៗ
អនិច្ចាតោថ្មលោកកសាង
មើលថាថាង(១)យ៉ាងរស់ស្លុះប្រែប្រាយ
ឥឡូវមកធ្លាយធ្លាក់បាក់ខ្ចាត់ខ្ចាយ
ស្តាយអើយស្តាយមិនគួរមកពិការ ៗ
មានអ្នកព្រៃបង្រៃឥតគំនិត
ទៅសំលៀងកាំបិតគ្រឿងប្រហារ
ឲ្យខូងខូចខាតសាបបង់អសារ
មិនស្តាយការស្នាដៃបុកណាសោះ ៗ
ទុតោអើយតោឈរមិនមើលមៀង
មកឲ្យគេសំលៀងខ្នងតោចុះ
ម្តេចមិនខឹងទាំងសំលៀងនោះ
ឲ្យវាលុះក្តីមរណ៍យកវាទៅ ៗ
អាណាអើយបំបាញរូបតោលោក

---

១—ថាថាង = កាយវិការ, ឬកា ។

គ្មានប្រយោគឲ្យយល់ការពក់ជ្រៅ
គួរឬលោកខំសាងតាំងទុកនៅ
មកសត្រូវបំផ្លាញរបស់លោក ៗ
គន់ ៗ ស្ថានស្ពានថ្មតប្រជិត
ជាក្ដារថ្មជាសជិតប្រកិតគោក
ទោះដំរីបរជាន់ក៏គ្មានយោក
ឥឡូវជ្រោកស្រុតខ្វះតែដើរបាន ៗ
បង្កាន់ដៃឆ្នរូបរាំសុក្រី(១)
ដប់សិរសីដូចស្និតជិតជុំប្រាណ
លើកពពារឡើងពក្ដាក់ហាក់ហោហាន
សំដែងប្រាណប្រញូរូបជាមួយគ្នា ៗ
មើលនាគពជអន់អាចអំណាចស្វែង
ខ្លួនក៏វែងក្បាលក៏វក់តាមទ្វារ
លូនលើស្ពានមានជើងកល់គង្គា
កន្ទុយបែកញែកគ្នាតាមផ្លូវ ៗ
ទរូបរាំសុក្រីឥតក្រែងគ្រុឌ

១— តាគជាទីតាំងព្រះតាភយណ៍ងទីនេះគឺ តាគ) ៗ

តាំងសម្ដែងរឹទ្ធិរទ្ធតសត្រូវ
ប្រសិនគ្រុឱមកយល់យ៉ាងពុំនៅ
គង់ស្ទុះទៅជ្រកក្នុងកសិណនេះ ៗ
នាគអើយនាគបាសាណបុក្កណសាង
ពីដើមយ៉ាងល្អឯកដូចម្ដេចអេះ
ឥឡូវនាគផាកធ្លាក់បាក់របេះ
ឃើញតែពងយ៉ាងនេះអស់លំអរ ៗ
ខ្លួនក៏ឃ្លាតក្បាលក៏ឃ្លៀងទៅដោយខ្លួន
ឃើញតែក្លួនដើងទៀនប្រចាំទ្រ
ស្ដាយអើយស្ដាយស្នាដៃលោកតែងមក
មិនតាំងតថាវរៈឲ្យវែងទៅ ៗ
ឱអនិច្ចាសង្ខារនាគាថ្ម
ហ្មាយតស្ថិតស្ថេរចីរកាលនៅ
នេះពុំទាន់ប៉ុន្មានមកហ្មងសៅ
មករុះពយធ្លាយទៅទីទៃផ្ដាស់ ៗ
មែនហ្ន៎សព្វសង្ខារក្នុងលោកិយ៍
មិនថាអ្វីតែកើតមកគង់វិនាស

ចុះត្រៃលក្ខណ៍ជាក់យ៉ាងពុទ្ធប្រកាស
សង្ខារចាស់គង់ផ្លាស់ទៅទីទៃ ៗ
អម្បាលថ្មគង់ប្រេះបេះបាន
ចំណាន់បើរូបប្រាណយើងសព្វថ្ងៃ
នឹងបានជាតិខ្លឹមសារឯណានៃ
គង់បន្ទៃដោយដៃពេគបិណ្ឌា(១) ៗ
កើតជាកាយគង់ធ្លាយសូន្យដីរ
បំពេញព្រះធរណីតែកល់គ្នា
គួរនឿយណាយបង្អន់ក្អើងលោកា
យកនាគានគរវត្តសង្កត់កាយ ៗ
ខ្ញុំពិនិត្យគិតផ្លូវព្រះត្រៃលក្ខណ៍
ចិត្តមិនធ្លាក់ឲ្យអារម្មណ៍ហ្មាយ
នៅតែស្ដុះម្ដង ៗ ដល់ឆោមឆាយ
ព្រោះឃ្លាតឆ្ងាយក្រែងឃ្លៀងលំអៀងទៅ ៗ
នុចិត្តខ្ញុំលោកិយដូចពានរ
មិនដែលឈឹងនឹងឈរឲ្យនឹងនៅ

ឃើញឯណេះទឹកឯណោះមិនចុះផ្លូវ
ថាតែក្រៅក្នុងមិនត្រេចភ្លេចក្ដីត្រេក ។
លុះដើរដល់កេងទងខ្វាងទ្វារប្រាង្គ
របៀងខាងយ៉ាងខណ្ឌកន្ទ្រងយ៉ែក
តួកណ្ដាលមុខដាច់ជាបួនប៉ែក
មានយ៉ែសែកបែកពុះជាពីរផ្លូវ ។
ប្រាង្គកណ្ដាលមានរូបទេពសិលា
គឺអ្នកតាមហាពជប្រចាំនៅ
បួនព្រះករកាន់គ្រឿងក្លសខ្លៅ
មើល ៗ ទៅគួរសម្បើមស្បើមមហិមា ។
ពួកអ្នកព្រៃពប់អានជាទេព្រក្ស
យកក្រជាសមាសប្រាក់អុជបូជា
បន់អ្នកតាមហាពជរឿងរំទ្ធា
សូមឲ្យកើតលាភាស្រីសួស្ដី ។
ខ្ញុំយល់រូបអ្នកតាហត្ថាសាយ
ទំនងព្រះនារាយណ៍រឿងរង្សី
ព្រោះបុកណពប់អានព្រះសូលី

ឥស្សូរាធិបតីតាំងជាមុខ ៗ
ពួកអ្នកព្រៃពុំស្គាល់យល់អំណាច
នាំគ្នាហៅមហារាជនៅទាំងស្រុក
ឲព្រះនារាយណ៍រឿងតេជវិសេសសុខ
ផ្ចាញវាមារទសមុខបានសុខា ៗ
មើលដំណាក់ប្រាង្គដាក់ព្រះនារាយណ៍
កំពូលបាក់ធ្លាក់ធ្លាយធ្លុះសុរិយា
ឥឡូវមានគេធ្វើជាបញ្ចា
ប្រក់ក្បឿងយើងធម្មតាការក្បៀងខ្យល់ ៗ
ទ្វារខាងត្បូងមានគ្រឹះប្ញសដល់ដី
បររទេះសាលីទាំងសកល
ទោះដំរីទាំងភូបក៏ត់តទាល់
ចុងផ្លូវដល់មុខនាគជាដើមព្រ័ត្រ ៗ
ផុតពេងទងរំលងខ្លោងទ្វារប្រាង្គ
លោកសំអាងសាងជាកំពែងព័ទ្ធ
តាមកសិណឡោមជុំនគរវត្ត
លោកកំណត់ទ្វារចេញជាបួនដាន ៗ

ចូលទ្វារប្រាង្គចេញខាងទិសបូព៌ា
មានថ្នល់ថ្មាទៅត្រង់មុខព្រះលាន
លោកវិចិត្រដោយថ្មកជាស្ពាន
សងខាងមានរូបនាគបង្កាន់ដៃ ៗ
រយៈផ្លូវសិនមួយមានផ្លូវញែក
ជាពីរប៉ែកបែកចុះទៅទីទៃ
ដល់កណ្ដាលមានប្រាង្គខាងស្ដាំដៃ
ពួកអ្នកព្រៃហៅថាៈពេងក្រយា ៗ
ប្រាង្គខាងឆ្វេងគេហៅពេងចំណី
មើលគួរបីសមពាក្យអ្នកព្រៃថា
មានផ្លូវចុះពីថ្នល់ដល់ដូចគ្នា
តែឥឡូវទៅជាព្រៃដុះជិត ៗ
ពេងព្រះស្មោយធ្វើដោយសិលាក្នុំ
តាំងជាមុមមុខបីជាបីស្និត
ឥតកំពូលមានដំបូលលោកវិចិត្រ
យ៉ាងសង្ខិតឥតកិតភាពស្មើផ្ទៃ ៗ
ទពេងគ្រួមិនគួរមកធ្លុះធ្លាយ

បាក់ខ្ចាត់ខ្ចាយអន្តរាយដោយពួរព្រៃ
គ្រាន់នឹងចូលទៅមើលក៏ស្ដុកក្រៃ
សែនអាល័យស្ដាយពេកខ្ទមអសារ ៗ
លុះដើរដល់មណ្ឌលផ្ទះបារាំង
លោកមកតាំងកសាងប្រាង្គថ្មដា
ឈ្មោះមោនសៀរកុម្ម៉ៃជាមេការ
ទៅភ្នាក់ងារទទួលជួសប្រាង្គណ៍ស្ថាន ៗ
លោកឲ្យជីកអាចម៍ដីដែលលុបថ្នល់
ដរាបដល់គ្រឹះថ្នល់ពីបុរាណ
ថ្មឯណាដែលបាក់ធ្លាក់ចាកស្ថាន
លោកឲ្យដាក់តាមដានសណ្ឋានចាស់ ៗ
លោកមោនសៀរកុម្ម៉ៃដៃបារាំង
យកស៊ីម៉ាំងលាបផ្សាប់ដូចក្រដាស
ឯណាស្រៃចាប់ខ្ទាំងមើលមិនច្បាស់
លោកឲ្យលាងបោសប្រាសសំអាតចេញ ៗ
ពួកគូលីស៊ីឈ្នួលជួលធ្វើការ

គាប់ឈើរើថ្មជាផាក់ពាសពេញ
ខ្ទះបោសធ្លាថ្នល់រលីងធិញ
អ្នកចូលចេញមិនមានដិតធូលី ៗ
ខ្ញុំដើរដល់យល់ថ្នល់លោកសំអាត
ឃើញពួកជាតិខ្មែរយើងជាគូលី
នឹកអាណិតជាតិខ្មែរក្រដល់ទី
ទទួលការគូលីស៊ីឈ្នួលគេ ៗ
គន់រូបពងទុពិលពោះកំប៉េះ
សក់ក្រញាញ់ខ្មៅក្រញោះផ្អែះដូចកេ
តាំងស្លៀកពាក់សំពត់ក៏ខុសគេ
ឥខ្មែរទេម្តេចខុសនឹងយើងម៉្លេះ ៗ
ឬពួកនេះជាជាតិសម្រែគួយ
អ្នកងារសួយលេខវត្តនគរនេះ
ឬជាពួងដែរគេកេណ្ឌរែះ
បានជាប្លែកយ៉ាងនេះគួរអនិច្ចា ៗ
លុះដើរដល់បណ្តាលទីពនហាល

ថ្មដាដាលក្រាលសឹងក្តារសិលា
ផ្ទៃពីដីពេជ្ររួតត្របកផ្កា
រៀបជាសារពើរសូត្រ(១)ថ្នាក់ ៗ ៗ
មានសរសេរថ្មឈូកជាញកចេញ
តាំងជុំវិញមានក្បាច់រំលេចដាក់
មានជណ្តើរកាច់ឡើងជាថ្នាក់ ៗ
បីប្រច័ក្ខឡើងចូលព្រះប្រាង្គស្ថាន ៗ
ផ្ទៃពនហាលកាលដើមបោះសំណ
លុះត ៗ ដល់យើងអន្តរធាន
បាក់សំណនៅតែថ្មក្រាលជាលាន
របៀបពនពថណែនសែនកំរម្យ ៗ
គន់ប្រាសាទស្អាតប្រសើរដំណើរប្រាង្គ
កំពូល ៥ បួនខាងខ្ពស់ត្រសុំ
ហានរួត ៗ ពល់ជាន់ជាពាន់ជុំ
ប្រាសាទធំតាំងកណ្តាលត្រដោមជុំ ៗ

---

១– សារពើសូត្រ = ឈ្មោះក្បាច់របតាមានសណ្ឋាន
របត់បីជ្រុង ។

រួតពីដីបីជាន់កេងខងជុំ
របៀងមុមមុខជាប់ក្បាច់រលង់
ជាហ្លូតហៀនវៀនរាំងកញ្ចាំងចុង
ល្អូកសម្បាកផែកសម្បុងជាខាន់ ៗ ៗ
ក្បាច់រង់ស្បូវទេពប្រណាម្យដៃប្រណិត
ល្អសប្រកបលាយប្រកិតក្បៀវល្ងិរ័ណ្ណ
បៃរកាបាំងរកិតស្និតរយពាន់
របៀងខាន់របៀបខាត់ចាត់ស្មើគ្នា ៗ
ហោជាងឆ្លាក់រូបយក្ខឆាក់ពានរ
យុទ្ធនារីកវរជាគោលា
រូបកហ្វូបៀមហៀនហង្សពាំផ្កា
យក្ខទេវតាទាញព្រ័ត្រវ័ទ្ធគីរិន្ទ ៗ
មេក្របទ្វារបង្អួចក្បាច់របក
លកក្របកផ្កាប់មុខដូចគេមិន
ផ្ដែក្ដារផ្ដរឆ្លាក់រូបកដទេវិន្ទ
កយុទ្ធទឹងអសុរិន្ទកដចក្រា ៗ

ផញ្ញាំងទ្វារថ្នាក់ផាទេពរបាំ
ក្រោយលំនាំឈររាំក្បាច់កាច់ផ្កា
ខ្លះប្អូនសក់ខ្ទក់បីបងផផា
ខ្លះសំយាកកេសាសិតក្របាំង ៗ
ខ្លះពាក់មកុដកំពូលបញ្ចាសិគ្គ
វែមុខក្រឡឹងភាពកញ្ចាំង
សូវងកងអង្កន់ព្រះហត្ថ
ស្បៀកសម្ពុយថ្នក់បាំងក្រោមនាភី ៗ
ចង្កេះវៀវផង្គន់ព៉ប់មួយក្ដាប់ដៃ
មើលវិសេសសុទ្ធវិស័យសមឥន្ទ្រិយ៍
សុតនក្បុំសមក្បួនទន្ទួនមាលី
ភាពនវេតកេទនារីទីស្នេហា ៗ
មានប្រុសយើងក្មេងកគវាពេលខ្លាំង
ទៅអង្គែល "មំសំ" នាងសិលា
ឡើងលេងសឹករលើងទាំងរូបា
គេសញ្ញាហៅថាស្រីមានលក្ខណ៍ ៗ
មើលមណ្ឌលពេងទងទំនងសុិម

ជញ្ជាំងជុំសឹងជិតជាចម្លាក់
ជារូបរឿងរាមកេរ្តិ៍គឺរាមលក្ស្មណ៍
ចំប្លាំងនឹងយក្ខក្រុងរាពណាសូរ ៗ
ស្វាប្រចាក់យក្ខប្រចាប់ក៏ប់រងគ្នា
ស្វាក្រទីយក្ខក្រទាកាប់ផ្លាស់ប្តូរ
យក្ខប្រជិតស្វាប្រដាប់ចាប់កំពូល
ស្វាប្រដាល់យក្ខដួលដេកក្សិណក្ស័យ ៗ
គន់គំនូររឿងរាមសង្គ្រាមយក្ខ
ជាអនគ្ឃ៍មើលអនេកអនន្តក្រៃ
ជ្រុងទក្សិណគួរកាលសហស្សន៍យ
គន់នៅញកៃឡាសវិមានចន្ទ ៗ
កៃឡាសផ្អៀងឆៀងធ្លាក់ព្រះសូលី
ប្រើក្រុងរាពណ៍អសុរីរាជកុម្ភណ្ឌ
ដៃម្ភៃមុខដប់រូបសកន្ធ
ឲ្យតម្រង់ប្រាង្គចន្ទកៃឡាសស្ថាន ៗ
រាពណានេរមិត្រឫទ្ធិសាហ័ស
តម្រង់ក្ដុំកៃឡាសឡើងត្រង់បាន

ព្រះឥសូរក៏ទ្រង់ព្រះរាជទាន
នាងមណ្ឌាកល្យាណជាភរិយា ។
ផ្ដែរខាងបូជាគួរកាលសុគ្រីពយំ
អង្វរអង្គព្រះបរមរាមា
ឲ្យជួយផ្សាញជីវិតនៃស្ដេចស្វា
ក្រុងពាលីដេជ្ឈាបច្ចាមិត្រ ។
ព្រះរាមក៏ប់បាច់ធ្នូរថ្វៃងសរ
បាញ់ពានរពាលីសូន្យជីវិត
គួរទាំងពួកនារីស្រីស្នំស្និទ្ធ
សោកអាណិតសែនអាណោចខ្មោចពាលី ។
ឯសុគ្រីពរំទ្ធីរទ្ធបុត្រសុរិយោ
ក៏សោកានៅទៀបព្រះទែនទ័
អញ្ជើញអង្គរាមាបូលធានី
តាំងពិធីលើកសពពានរ ។
ឯជញ្ជាំងខាងត្បូងគួរព្យូហបាទ
ដៃរ្ហែអង្គនរនាថកេតុមាលា
លើកជាក្បួនព្យូហយុទ្ធនា

គ្រប់គា សាចូលពឹងព្រះបារមី ៗ
ខ្ញុំគន់មើលព្រះកេតុគេបិទមាស
គង់លើអាសន៍កណ្ដាលពួកសេនិយ
សែនរុងរឿងថ្កើងបុណ្យព្រះចក្រី
ជាអស្ចារ្យផែនដីសកលអាយ ៗ
អង្គនេះឬគឺជាបឋមក្សត្រ
គ្រងសម្បត្តិឥន្ទបតវិសេសសាយ
ទ្រង់សាងព្រះនគរវត្តដ៏ឆើតឆាយ
ស្ដេចលើកថ្វាយព្រះពុទ្ធឃោសា ៗ
កាលលោកទៅចម្លងព្រះគម្ពីរ
អំពីរាជធានីកោះលង្កា
វិលមកដល់ប្រទេសខេមរា
បមក្សត្រានិមន្តឲ្យពេកកនៅ ៗ
លើកប្រាង្គនេះប្រគេនជាមណ្ឌល
ទីតម្កល់ព្រះគម្ពីរគម្ពីរជ្រៅ
ពុទ្ធឃោសាបារ្យលោកគង់នៅ
បានជាហៅនគរវត្តដោយកំណត់ ៗ

ព្រោះប្រាជ្ញនេះពីដើមជានគរ
ដល់ក្រោយទ្រង់សាទរថ្វាយជាវត្ត
ពួកបុរីនាំគ្នាមកសន្មត
ហៅប្រាសាទនគរវត្តតាមបទមាន ។

ឱព្រះគុណព្រះកេតុមាលាក្សត្រ
ព្រះទ័យកាត់ពុំស្ដាយព្រះរាជស្ថាន
ថ្វាយជាវត្តស្រេចស្ដេចចេញឋាន
ទៅតាំងស្ថានព្រៃក្មេងបេងមាលា ។

ឥឡូវសូន្យព្រះយសឈ្មោះបាត់បង់
ឃើញតែរូបព្រះអង្គគង់ច្នេះណា
ខ្ញុំបាទយល់សរសើរព្រះចេស្ដា
លើកហត្ថាបង្គំគុណក្សត្រថ្លៃ ។

គន់មើលព្រះកេតុមិនឆ្អែតក្ដីសន្ទិះ
ឱប្រាជ្ញនេះមើលទៅផុតនិស្ស័យ
យើងឥឡូវគិតទៅអចិន្ត្រៃយ
មិនគួរទៅជាព្រៃសូន្យអសារ ។

យ៉ាងពីដើមមនុស្សច្រើនចំរើនចេះ
បានជាធ្វើប្រាង្គណ៍នេះគួរអស្ចារ្យ
ស្នាដៃធ្វើមើលស្មើព្រះពិស្ណុការ
តប្មជាស្បូលដែកសែកគ្នាជាប់ ៗ
ពោះក្នុងថ្មតផ្ចិតលោយសាច់
ដល់យូរមកដែករេចរោយច្រេះចាប់
នៅតែព្រន់អ្នកព្រៃប្រាជ្ញាគាប់
ថាស្នាមម្រាមដៃចាប់មនុស្សបុរាណ ៗ
ខ្លះសង្ស័យថាដៃព្រះឥន្ទ្រប្រើ
ឲ្យវិស្សកម្មធ្វើថ្វាយក្សត្រក្សាន្ត
ខ្ញុំគន់ៗ មើលសព្វមន្ទីរស្ថាន
មិនសមដៃមយកន់លោកធ្វើឡើយ ៗ
ព្រះឥន្ទ្រអ៊ីមកធ្វើមិនឲ្យស្រេច
មើលទៅក្បាច់ខុសគ្នាណាលោកអើយ
ខ្លះអាក្រក់ខ្លះល្អមិនស្មើឡើយ
បើព្រះឥន្ទ្រធ្វើហើយគង់ស្មើគ្នា ៗ
មួយវិញទៀតវិស័យទេពនិម្មិត

ធ្វើដោយរឹទ្ធិគិតថ្វាយស្តេចអង្គណា
តែស្តេចនោះលុះអស់ព្រះជន្មា
ទីនិម្មិតទៅជាផែនដីវិញ ៗ
នេះប្រាសាទនគរនៅជាគឺ
នឹងថារឹទ្ធិនោះបុយ៉ាងនេះមិញ
បើរឹទ្ធិមែនម៉្លេះសមរលីងធិញ
ទីនេះមិញក៏ពេញទៅដោយព្រៃ ៗ
សង្ស័យថ្វីនឹងដុំថ្មធំ ៗ
គេលើកយកទៅផ្គុំបានទាំងផ្ទៃ
គឺគេប្រើដោយយន៉្តករវៃ
នឹងបានប្រើដោយដៃនោះក៏ទេ ៗ
វិស័យជាងគេបេះគ្នាគេច្រើន
ស្តេចចំរើនដោយបុណ្យពីបុព្វេ
នឹងធ្វើអ្វីក៏ស្រេចចំណោះគេ
កុំទៅគ្នេថាអង្គព្រះឥន្ទ្រសាង ៗ
មានអ្នកខ្លះចូលចិត្តថាដីពិត
គឺគេដុតយ៉ាងឥដ្ឋជាថ្មប្រាង្គណ៍

ព្រោះឃើញទឹកសិណដ៏នៅខាង
ទំនងយ៉ាងយកដីកសិណនោះ ។
ទហ៊្នជាតិអ្នកខ្វៅដៅមិនចំ
ម្តេចមិនមើលបែបពុម្ពតូចធំបណ្ណោះ
មែនបើដីគេធ្វើមានពុម្ពនោះ
គង់ប៉ុនគ្នាអស់នោះមិនបណ្ណោះប្ត ។
នេះមិនមែនប៉ុនគ្នាជាបែបពុម្ព
ខ្លះក៏ធំខ្លះក៏តូចនៅជាគឺ
បុកណាអ្វីឆោតម៉្លេះមិនដែលត្រ
មកប្រឹងធ្វើជុំធំឲ្យធ្ងន់ក្រៃ ។
បើយ៉ាងថ្មបាយក្រៀមនោះយល់មែន
ព្រោះផ្ទៃផែនស្មើគ្នាទាំងអស់នៃ
ឯថ្មផុកអ្នកស្រុកកុំសង្ស័យ
គឺស៊ីមង្គថ្មព្រៃយកពីក្រៅ ។
បើមិនជឿអញ្ជើញទៅមើលដាន
ក្នុំខាងលើសឹងមានចំណាំងនៅ

ទាំងថ្មហ៊ុបថ្មដាប់គរតាមផ្លូវ
មានគេទៅបានឃើញជាអស្ចារ្យ ៗ
ខ្ញុំគន់មើលគំនូរគួរជញ្ជាំង
លើសកម្លាំងនឹងតែងឲ្យពិស្តារ
វិលត្រឡប់ទៅមើលជាន់កណ្តាល
ឃើញព្រះពោធជ្រះប្រាលក្រសាលលន់ ៗ
ដើមសសរឆ្លាក់រូបឥសីសិទ្ធិ
អង្គុយបត់ជើងបិទប្រសិទ្ធិមន្ត
ផ្ទៃសសរមានអក្សរប្រកាសបុណ្យ
ឲ្យមហាជនមើលដឹងដំណឹងទី ៗ
មានសកករាជក្នុងរាជស្តេចជាន់ក្រោយ
ទ្រង់អំណោយសាងព្រះសាងគម្ពីរ
បានលែងមនុស្សជាខ្ញុំថ្វាយព្រះមុនី
តាំងសញ្ញាឈ្មោះទុកនៅមុខព្រះ ៗ
លើពិតានថ្នមខាត់ចាត់ក្បាច់ផ្កាយ
ល្អកសាពយលាយលយលកល្បះៗ

គ្រឹះប្រដាប់ប្អូនប៉ែកបែកស្រឡះ
បន្ទោះជ្រុងមានស្រះជាប្អូនដាន ៗ
ឯស្រះនោះមានដក់ទឹកភ្លៀងស្អាត
មច្ឆាជាតិអាស្រ័យនៅជាស្ថាន
ឥតបកក្រាំស្មៅព្រៃកក់ផង់គ្មាន
ផ្ទៃសណ្ឋានប្អូនជ្រុងស្មើភាគគ្នា ៗ
លោកប្រដាប់ដោយថ្មកដល់បាទ
រលីងស្អាតសឹងរូតហូតពេជា
មានកើយកែវដណ្តើរចុះគង្គា
មើលហាក់ជាស្ថានជ្រៅអណ្តូងជ្រោះ ៗ
ខ្ញុំយល់គ្រីសង្ស័យហ្វូងមច្ឆា
មកពីណាទៅមានក្នុងស្រះនោះ
ស្រះលើប្រាង្គណ៍ផុតជាតិផែនដីសោះ
ទឹងមានជ្រោះហូរជ្រាបក៏គ្មានមុខ ៗ
ត្រីពួកនេះឧប្បត្តិកកើតឯងឬ
ឬមួយគឺគេយកមកលែងទុក

ខ្ញុំពិគ្រោះពុំឃើញមានទំនុក
សែនជាទុក្ខទឹងត្រើពេញអស្ចារ្យ ។
នឹងមានអ្វីជាចំណីអាស្រ័យបាន
បកសាកយកក៏គ្មានជាអាហារ
មានតែស្លែដុះជាប់តាមថ្មជា
មើលអាការស្រះនោះជារណ្ដៅ ។
មានពេងតាំងបួនមុមដុំស្រះស្រង់
ខ្នងបង្កង់ជាប់គ្នាជាបួនផ្លូវ
ទ្វារឧត្ដរមានជ្រុងក្នុងយ៉ាងជ្រៅ
នរណាទៅគោះទ្រូងពុសូរគង ។
មានអាការអស្ចារ្យទីនោះម្ល៉េះ
បុរាណរិះបេះធ្វើមានទំនង
ផ្ទុកបស្មើពុំឃើញមានអ្វីវេង
គោះតែទ្រូងពុគងសូរលាន់ៗ ។
ពេងខាងត្បូងតម្កល់ព្រះបដិមា

ពុទ្ធបាទសាស្តា ហៅព្រះពាន់
អង្គខ្ទះឈរខ្ទះគង់សង្រួមខន្ធ
មានអរហន្តគង់គាល់ទាំងឆ្វេងស្តាំ ។
អង្គព្រះខ្ទះពិការបាក់សូរង
នៅតែដងអងកាយគង់ប្រចាំ
ព្រះខ្ទះឈរកណ្ឌៀវស៊ីសាំ
បែកព្រះកាយបាក់ព្រះកាំស្រាំព្រះករ ។
មុខសថូបមានរូបច័ក្រពង្ស
ពីរព្រះអង្គគឺព្រះកេតុបៅនគរ
គង់ប្រណម្យបង្គំលើកព្រះករ
ទនស្មោះសរគុណព្រះជិនស្រី ។
តែរូបព្រះអង្គមួយដែលទ្រង់គ្រឿង
ពាក់ជដារុងរឿងរឿងរង្សី
ខ្ញុំពុំស្គាល់ព្រះនាមជាស្តេចអ្វី
គ្មានបារីកទឹងស្តីថាស្តេចណា ។
គន់ព្រះរូបចិត្តរួញកន្ត្រួញក្រាប

សិរពេកបបង្គំព្រះសាស្ដា
សូត្រសរសើរពុទ្ធគុណអនន្តា
ស្រេចទើបលាឡើងទៅជាន់ទី ៤ ៗ
បានខាងលើលោកធ្វើជាផ្ទៃកាន
ដួរជុំមានសសរពេញដោយខ្លួន
សឹងក្រឡឹងជើងទៀនដ៏មាំមួន
មើលចំនួន ប្រមាណជារយប្លាយ ៗ
ខាងឆ្វេងស្ដាំមានកឹងទាំងពីរជាប់
ប្រកបក្បាច់ក្អក់ហៀននិងលួសលាយ
តួកឹងនោះឥឡូវបាក់ធ្លាក់ធ្លាយ
គួរតែស្ដាយកឹងថ្មអន្ទរជាន ៗ
មើលបរិវេណចង្អាត់ព្រះប្រាង្គណ៍ធំ
រោងទងជុំតាមជាន់គ្រប់ ៗ ជាន
មានញកញោចរួតពេជ្រតាមសណ្ឋាន
លើសប្រមាណទឹងរាស់គត់និយម ៗ
គន់ទីបួនប្រាង្គណ៍ ៤ ចតុរស

កំពូលខ្ពស់ស្មើគ្នាទាំង ៤ មុម
ខ្ញុំក៏ឡើងជាន់ ៥ ប្រាសាទធំ
ខ្ពស់ត្រសុមមើលត្រសែតអណ្ដែតចិត្ត ៗ
ភាពជណ្ដើរឡើងទៅក៏ខ្ពស់ចោត
កាំនោះសោតតូច ៗ កាន់មិនស្និទ្ធ
បង្កាន់ដៃពុំមានទឹងយោងយិត
ខំកខិតឡើងទៅត្រាតែដល់ ៗ
គន់ជណ្ដើរឡើងទៅប្រាំបួនស្ពាន
ក្នុង ១ ជាទពីរ ៗ ជុំមណ្ឌល
មានរូតផ្ទាក់ល្បាក់ញកលោកតម្កល់
ជាតើងទល់ទាល់ដល់បង្កាន់លើ ៗ
គួប្រាង្គណ៍ទាំង ៥ យ៉ាងចេតិយ៍
រូតប្រាំបួនជ្រុងប្រាំបីជាស្មើ ៗ
ខឿនប្រដាប់ពេជ្ររូតច្រើនអន្ទើ
ត្របកស្មើជ្រុងមុមទាំងបួនជាន ៗ
មានទ្វារចូល ៤ ទិសតែគេទាស់

បិទជិតអស់មិនឲ្យចូលជិតបាន
ស្អាងជាអង្គព្រះឈរប្រតិស្ឋាន
ប្រចាំដានគ្រប់ទិសទាំង ៤ ទ្វារ ។
ខាងក្នុងប្រាង្គណ៍យ៉ាងជាក់ព្រះមាសប្រាក់
ដែលបែកបាក់ធ្លាក់បង់អង្គពិការ
ឬរបស់ឯណាជាខ្ទឹមសារ
ក្រែងពួកចោរពួកមារពាយាយី ។
លោកមោនសៀរកុម្ហ៉ៃហៅភ្នាក់ងារ
ឲ្យជាប់ទ្វារខាងត្បូងរូបព្រះដីរ៍
រំលើងអង្គព្រះទ្វារចេញចាកទី
ហើយកព្រះខ្ទួចខ្ទីពីក្នុងប្រាង្គណ៍ ។
ខ្ញុំយល់អង្គព្រះទ្វារគេជាប់ផ្ដាច់
បាក់ស្បូវរងរូបខ្ទួចមិនយល់ពង
ទឹកសង្វែកព្រះទ្វារគេរំលាង
ផុតរវាងសាសនាព្រះទ្វារហើយ ។
ព្រះទ្វារទាំងបីលោកគង់សុខ
ពុំមានទុក្ខដូចអង្គព្រះត្បូងឡើយ

ទព្រះត្បូងពីថ្ងៃនេះទៅមុខហើយ
រំលត់ខន្ធកាន់ត្រើយនិព្វានហោង ៗ
ខ្ញុំខំចូលទៅមើលកន្លែងគុក
ដែលគេតាំងព្រះទុកពុំឲ្យហ្វង
មើលមិនច្បាស់ព្រោះជះក្លិនម្ដង ៗ
គឺប្រចៀវខ្មៀវកងរាជទ្វារ ៗ
ទើបលាយថយចុះមកគ្រឹះធរណី
មើលពួកខ្មែរគូលីគេធ្វើការ
ជញ្ជូនយកអាចម៍ដីគឺទ្វារ
ចេញតាមទ្វារទិសបូពិបន្ទ្រគ្គា ៗ
គន់មណ្ឌលព្រះប្រាង្គណ៍យ៉ាងល្វាល ៗ
ពេលក្របីចូលក្រោលអស់សុរិយា
ខ្ញុំនាំគ្នាចុះមក កាន់ពសុធា
ទៅរកទីនិទ្រានារាត្រី ៗ
លុះព្រឹកឡើងជាថ្ងៃមួយដណ្ដប់

តិត្ថីជូនគំរប់ថ្ងៃសៅរ៍
លោកទៅហ្វាយក៏ដល់មណ្ឌលថ្មី
ថែងសេចក្តីថាថ្ងៃនេះហ្លួងដល់ ។
ខ្លួនលោកមកជាមុនដោយប្រញាប់
ទឹងអាលមកចាត់ក៉ប់ឯមណ្ឌល
ស្តេចទឹងយាងមកតាមវិថីថ្នល់
កំណត់ម៉ោង ១១ ដល់ព្រះពន្លា ។
លុះនិយាយបានតិចលេចកៅរ៍
ជិះញាជីមកដល់ថែងកិច្ចា
ជំពបលោកសក្តិបីពជអាជ្ញា
ថាឲ្យរៀបព្រះពន្លាស្តេចដល់ឆាប់ ។
លោកសក្តិបីព្ទោះស្ទុះម្នីម្នា
ហៅពួកក្រុមយោធាជាប្រញាប់
ព្រមទាំងពួកខុនណាងគ្រប់សម្រាប់
ឲ្យរៀបខ្លួនឈរក៉ាប់ព្រះបក្រី ។
ក្រុមទាហានក៏រៀបក្បួនសៈលុត
ឈរអាវុធវន្ទិយាតាមថ្នល់ថ្មី

ពួកអ្នកស្រុកក៏ផ្អើលទាំងប្រុសស្រី
មកចាំមើលចក្រើមីរត្រៀបត្រា ៗ
ខ្លះក៏បីកូនតូចដឹកកូនធំ
អាតូចយំអាធំយឹតស្ទើរជាប់ស្មា
ខ្លះក៏បាត់ប្អូនឃើញបងរកគ្នាថ្វា
ខ្លះឃើញយាយបាត់តាហៅគ្នាសា៊ន ៗ
ខ្ញុំគន់ ៗ អ្នកព្រៃបង់តែសើច
ត្រកូលទើបមើលខាតខុសសណ្ឋាន
ទាំងស្លៀកពាក់មិនសមនឹងខ្លួនប្រាណ
សែនរំខានទាស់ភ្នែកប្លែកកន្ទង ៗ
មានយាយចាស់ខ្លះនោះរូបពញ្ញក់
ទៅពាក់ការទំពក់ដូចគេបង
ពាក់អង្កាំបារស្តាខ់ព័ន្ធកម្រង
មើលម្តង ៗ ចុះគន្ទង់ព្នងពិត ៗ ៗ
ឲអ្នកព្រៃតែងត្លួតតសំណាំ
ពុំចេះរៀបចេះបំតាមចរិត
គន់អ្នកព្រៃមិនអស់ក្តីអាណិត

ហេតុតែក្រពិត ៗ ទើបយ៉ាងនេះ
អនិច្ចា អ្នកក្រត្រដរមក ។
ខំប្របៀតជ្រៀតជ្រកទឹងគេច្នះ
ខ្ញុំសម្តេចបានតិចលេចឃើញសេះ
ក្រមការគេជិះជាមគ្គុទេសក៍ ។
ឃើញព្រះទីនាំងរាជរថពីរបវរ
ទឹមអស្សត្ថរបរចូលដល់និវេសន៍
ទ្រង់យាងចុះលោកធំបាកំងសែស
តំនាប់តាមប្រទេសវេណីក្រៅ ។
នាយទាហានក៏ស្រែកក្បួនសៈលុត
ចាប់អាវុធវន្ទីយាបញ្ឈរនៅ
ពួកនាប៉ឺនទុនកាយបង្គំទៅ
ទ្រង់ព៉ប់ផ្លូវបដិសណ្ឋារ ។
លោកសក្តិបីទទួលទីព៉ប់រង
ជាបាល័ដ្ឋទូលស្នងការនានា
តំនាប់ស្រេចឡើងកាន់ព្រះពន្លា
អស់ព្រះពញាហៃឡើងដំណាក់ស្ពាន ។

ដល់ព្រះទែនស្តេចទ្រង់គង់កៅអី
លោកសក្តិបីអនុកូលទូលរ៉ាយង៉ាន
រឿងអ្នកទោសដែលជាប់ពីក្រៅស្ថាន
កាលពីស្រុកមោះមានអាចោរខ្លាំង ៗ
លោកឲ្យចាប់ទាំងជាទាំងកាចបក
ព្រោះប្រាថ្នាដកយកស្បៀងកម្លាំង
នៃអាចោរទុច្ចរិតគិតតតាំង
កាត់កម្លាំងពួកចោរមិនឲ្យទៅ ៗ
បានជាកៀរគ្រួមកព្រះដំបង
ដាក់ទោសតាមទំនងដែលហួងសៅ
ចាំស្រុកពបកាលណានឹងលែងទៅ
ដល់ឥឡូវស្រុកក្សាន្តបានសុខា ៗ
គួរមេត្តាយ៉ាងណាស្រេចតែទ្រង់
ឬបង្អង់ឈប់រង់មើលក្សិណក៏
ព្រះបមយសជ្រាបហ្នោះទ្រង់មេត្តា
ឲ្យលើកកាត់ទោសាពួកអ្នកព្រៃ ៗ
សន្ទនាបានតិចតាមនុសន្ទ័

ឲ្យនិមន្តព្រះសង្ឃចូលថ្វាយជ័យ
ជយន្តោថ្វាយពរក្សត្រថ្លាថ្លៃ
តាមនិស្ស័យវេណីពីបុរាណ ។
លោកសង្ឃយើងព្រះដំបងដប់អង្គគត់
វិន័យធរដើមបទជាប្រធាន
រៀបព្រះអង្គចូលកាន់ព្រះវាំងស្ថាន
ទទួលក្តីពប់អានតបក្រា ។
ទើបថ្វាយព្រះជយន្តោពរភវ័ត
បំរើនរាជពិភ័តមង្គលា
លុះចប់ស្រេចស្តេចត្រាស់សន្ទនា
ឲ្យសង្ឃលាទៅស្រុកតាមសម័យ ។
ព្រោះក្រែងដាច់វស្សាការសៅហ្មង
តាមទំនងសត្តាហប្រាំពីរថ្ងៃ
លោកសក្តិបីទទួលទូលកែខៃ
សូមអំណាចក្សត្រថ្លៃឃុំរក្សា ។
បក្រពង្សព្រុំទ្រង់ឲ្យអំណាច

ព្រះទ័យខ្វាចក្រែងខុសក្នុងសិក្ខា
តែសត្តាហព្រះដំបងហួសហើយណា
ហួងនឹកថាក្រែងលោកទើបដល់ថ្មី ៗ
ពុំជ្រាបហេតុព្រះសង្ឃព្រះដំបង
មកនៅចាំព៉ប់រងព្រះចក្រី
តាំងពីខ្នើតមួយកើតចូលតិត្តី
ដប់មួយសៅរ៍ហួសកំណត់ ៗ
សត្តាហបានតែប្រាំពីរថ្ងៃ
នេះហួសផុតនិស្ស័យសិក្ខាបទ
ថ្ងៃហួងដល់ដប់មួយកើតប្រាកដ
បើកំណត់សត្តាហហួសបួនថ្ងៃ ៗ
ហេតុដូច្នោះលោកសង្ឃព្រះដំបង
ដាច់វស្សាហើយហោងកុំសង្ស័យ
ខ្ញុំព្ទុច្នោះអាណិតលោកពេកក្រៃ
ឱម្ចាស់ថ្ងៃគ្រងកឋិនឃើញជាខាន ៗ
មួយអាណិតតែលោកវត្តនិវេសន៍
ជាប្រទេសមង្គលបូរីស្ថាន

ត្រូវទោសខុសកាលស្រុកកើតមោះមាន
ពួកគាហានបាញ់បោរវរកល្បុគ ។
លោកភ័យលោករត់ទៅនៅណោងបួ
ដល់ស្រុកពបនាំគ្រួសិស្សវិលស្រុក
លោកពជការថាលោកនាំកល្បុគ
ឲ្យឃុំខ្លួនមកទុកព្រះដំបង ។
ឃាំងនៅវត្តពីកិតជាយូរខែ
ទម្រាំតែផុតទោសដែលមោះហ្មង
មិនដឹងជាថ្ងៃណាទីងរូបហោង
សែនមួហ្មងចង់វិលទៅវត្តវិញ ។
រកឱកាសពុំបានរំខានចិត្ត
សែនអាណិតគិតទៅគួរតែម្នេញ
លុះព្ធការថាហ្វងស្ដេចយាងចេញ
ចាកក្នុំពេញមកផ្ទុំនគរវត្ត ។
បានឱកាសដោយបេះក្សួនវន្ទា
កាំជ្រួចភ្ជីគោហៀសម្រែកសត្វ
លោកវត្តលៀបមេការទីបាល័ង្គ

លោកក៏ចាត់ឲ្យទៅជាមួយផង ។
ឲ្យលោកជួយការក្រីទីចុងបុណ្យ
ថ្វាយព្រះគុណជាគុណព្រះប្អាស់ប្អូន
បានឱកាសនឹងទូលសូមទោសហោង
នឹងបានវិលទៅគ្រងនិវេសន៍វិញ ។
លុះព្រុហ្វូនប្រោសលែងអ្នកទោសបង់
ទាំងបាសកលោកសង្ឃដូច្នោះមិញ
មួយលោកសង្ឃបីអង្គនៅភ្នំពេញ
ឲ្យវិលវិញមកនៅតាមដើមដាន ។
ចៅអធិការនិវេសន៍ក៏ស្បើយទុក្ខ
មានទឹកមុខរីករាយសប្បាយបាន
ថ្វាយព្រះពរលាអង្គបមក្សត្រក្សាន្ត
វិលទៅស្ថានទីលំនៅនៃអាត្មា ។
បមរាជសន្ទនានឹងព្រះសង្ឃ
លុះសូរិយង្គរះរេជ្រេឆាយា
សង្ឃទាំងឡាយក៏ថ្វាយព្រះពរលា

ព្រះកជាទ្រង់សោយដោយសម័យ ៗ
ស្ដេចទ្រង់សោយព្រះស្ងោយវេលាជ្រេ
សូរេចសោយសុរិយាជ្រេស្រន់ថ្ងៃ
ទ្រង់បន្ទុំសម្រាន្តព្រះហឫទ័យ
ពួកខាងណៃ ទាញផ្ចិតផាត់ថ្វាយទ្រង់ ៗ
សែនកំសាន្តក្សាន្តកិរម្យបរមនាថ
ព្រះពាយផាត់គន្ធជាតិពិដោរហ្វង់
មហោរីប្រគំបន្ទន់អង្គ
ចក្រពង្សទ្រង់ផ្ទុំកិរម្យខ្វីន ៗ
លុះទិនករបរបែរជ្រេរស្មី
ព្រះចក្រីតើនចាកខែនសុវណ្ណ
តែងព្រះអង្គចេញគង់ចុងរោងច័ន្ទន៍
ពួកកំណាន់គាល់ព៉ប់ស្ដាប់ទង្គារ ៗ
អស់ជំនុំមន្ត្រីកុងស្រួយជំ
មកដល់ជុំចាត់ទីតាមមុខងារ
ក្រុមប៉ូលិសតាំងនៅប្រចាំទ្វារ

មើលត្រួតត្រាក្បាសត្រូវទ្រង់ ៗ
ពួកក្រុមរាំងលោករាំងនាយចាងហ្វាង
ភ្នាក់ងារខាងស្តីការស្នំខាងក្នុង
ក្រុមតម្រួតនាយត្រួតព្រះដំរង្គ
លោកព្រះស្តេចស្តីការសង្ឃការី ៗ
អគ្គពជយមរាជក្រុមមឿង
សត្រីវឿងអាជ្ញាការផែនដី
ក្រឡាហោមចក្រីទីកុង្សៀយ
ភ្នាក់ងារស្តីតាមទីបតុស្តម្ភ ៗ
ឯខុនណាងខាងក្រៅណាកដំណែង
ភ្នាក់ងារតែងគ្រប់មុខទាំងតូចធំ
សឹងព្រមព្រៀងនៅរៀងរោងថែវធំ
តាមក្រុម ៗ ខ្ញុំពុំស្គាល់ទេលោកអើយ ៗ
គ្រាន់ចឹងតែងឲ្យគ្រប់ឈ្មោះអស់លោក
គិតប្រយោគទៅទៀតពុំបានឡើយ
ពេលក៏ជួនចុះយប់ព្រលប់ហើយ

ខ្ញុំក៏នឿយវិលទៅទីនិទ្រា ៗ
ពេលយប់នោះការហ្វូងទើបដល់ថ្មី
ក្រុមមន្ត្រីសម្រាកតែពល់គ្នា
ពុំទាន់មានរាជការទឹងពណ៌នា
ខ្ញុំនិទ្រាលក់ទៅតាមសម័យ ៗ
លុះព្រឹកឡើង ១២ ថ្ងៃអាទិត្យ
ចមបពិត្រព្រះកែវហ្វាសុឡាឡៃ
ស្តេចរៀបគ្រឿងពលីការបូជាសេយ្យ
សូមពរជ័យទេវតារក្សាស្ថាន ៗ
មួយបូជាព្រះពាន់តុទ្ធរូប
នូវព្រះស្តូបចេតិយពីបុរាណ
ទាំងអ្នកតាមហារាជវត្ថិហាន
តាមលំអានបុរាណរាជវេណី ៗ
លុះដល់ថ្ងៃ ១៣ តិត្ថីជួន
ពួកខុននាងរៀបខ្លួនគ្រប់នាទី
ចាំទទួលលោកធំចៅធានី

គូវៃវណើរមកពីព្រៃនគរ ៗ
លុះលោកដល់ក៏ចូលទីប្រជុំ
ពួកមន្ត្រីតូចធំគ្រប់ទិករ
សឹងទទួលគំនាប់ដោយសាទរ
ចមនគរក៏ទ្រង់ត្រេកគំនាប់ ៗ
លោកសក្តិ៣ ថែមចីបកភាសា
បែងកិច្ចាទទួលក្រសែសត្វ
ចក្រពង្សក៏ទ្រង់គង់ប្រថាប់
តាមព្រះច្បាប់ស្តេចទ្រង់គង់ស្តាំដៃ ៗ
លុះសុរេចសន្ទនាវេលានោះ
គូវៃវណើរលាចុះឡើងរថវៃ
ទៅផ្ទះខានត្បូងព្រះរាំងជ័យ
សម្រាប់ទីអាស្រ័យបាំងនៅ ៗ
ខ្ញុំមើលសក្តិប្រាំចាំមិនជាក់
ឃើញតែពាក់គ្រឿងសក្តិប៉ាក់ប៉ានខ្មៅ
រូបលោកទាបភាពធាត់មាត់ស្រមូវ

មើល ៗ ទៅគួរខ្លាចពុំអាចជិត ។
គេចមកមើលអ្នកលេងល្បែងបៀប៉ោ
ខ្លះក៏ចាញ់សោហោប៉ៅស្វិត
ខ្លះបានឈ្នះក៏ត្រេកតម្រេកចិត្ត
ខ្លះរេគិតកែកុនដោយកលកោង ។
ខ្លះឈ្នះប៉ោចាញ់បៀសសៀរដួ
ចាក់មួយតៅខុសមួយតួក៏ស្បើយស្បោង
បែរត្រឡប់ប្តូរប្រាក់ចាក់អាប៉ោង
ត្រូវចិនកោងអស់ប្រាក់ខ្លាក់ចង្កា ។
ចាប់យីគីស៊ីមួយសងដល់ដប់
ចិនប្រសប់ខ្នរកែបញ្ញា
ទោះជាត្រូវយូរទៅគង់អបរា
បានដៃរាជាក់ថង់កុំសង្ស័យ ។
ខ្ញុំមើលគេរេគិតដល់ខ្លួនឯង
មិនគួរលុះការល្បែងឲ្យចង្រៃ
ទុកទិញបាយចំណីត្រីអាស្រ័យ

យល់ជាមានកម្រៃបានឆ្អែតពោះ ៗ
ឯជាតិល្បែងលេងភ្នាល់មិនទាល់ចេះ
ឈ្នះឯណោះចាញ់ឯណេះមិនខានសោះ
ការលោភលន់គន់លាញប្រទាញឈ្មោះ
តែដល់គ្រោះគន់ក្រកម្រក្រៃ ៗ
ខ្ញុំមើលគេបានតិចគេចទៅផ្សារ
ទិញចំណីអាហារបាយអាស្រ័យ
សូរេចកិច្ចសុរិយេជ្រេមាត់ព្រៃ
បាត់សែងថ្ងៃខែខរង្សីសែង ៗ
ចៅភ្នាក់ងារនាំគ្នាតែងពេងកាំ
ទាំងពេងទងធ្វេងស្តាំសឹងខ្វាត់ខ្វែង
អុជប្រទីបថ្លាលាភ្លើងភ្លឺថែង
ជាដួរវែងដល់ចុងផ្ទះបារាំង ។
លើខ្លោងទ្វារអុជជាត្រាផែនដី
មកុដច័នរង្សីព្រះពានតាំង
ស្វេត្រច្ឆ័ត្រធ្វេងស្តាំប្រចាំបាំង

ភ្លឺទូទាំងរាជវាំងត្រឆាឆាយ ៗ
មើលពន្លឺកគ្រឹកគ្រឹនអនេកក្រៃ
ស្វាងតែព្រៃផាលផាសទុកាសសាយ
បណ្ដាពួកប្រុសស្រីផងទាំងឡាយ
សឹងសប្បាយនាំគ្នាមើលត្រៀបត្រា ៗ
លុះដល់ពេលហ៊ុមពេងភ្នាក់ងារហោ
គេរីពេទ៏ណៃណាគដើតឈឹងឆា
ពួកអ្នកស្រុកក៏ចូលមើលត្រៀបត្រា
ណៃនទាំងមហាពជពេងកងសព្ទសៃ ៗ
សឹងប្របៀតជ្រៀតគ្នាដែកមិនចុះ
នរណាលុះក៏ស្ទុះទៅមុខគេ
នរណាខ្លាចមិនអាចប្របៀតទេ
ត្រូវឈរមើលក្រោយគេឃើញត្រដរ ៗ
នរណាខ្ពស់គេគ្រាន់មើលស្រួលពប
នរណាទាបតោងរកដើងម៉ា ត
បើស្រីណាកាន់ខ្លួនថាទួនល្អ

តែចូលទៅក្នុងបគង់អប្រិយ៍ ៗ
ពួកអ្នកលេងរាតែងដើរត្រដុះ
ជាច្នេះច្នោះឲ្យលុះការលោកិយ៍
ខ្ញុំយល់ៗ អាណិតពួកស្រី ៗ.
ប្រុសអប្រិយ៍យាយីជាទីហ្មង ៗ
ខ្វះមានញាតិបងប្អូនជូនព្យាបាល
វក្យា ការពួកពាលកុំកន្វង
ឯណាគ្មានពូជពង្សវង្សផៅផង
ពាលរាលងឲ្យកល្បួនកួនដោយកាម ៗ
អនិច្ចានារីរូបស្រងាំ
មិនគួរមកមើលរាំឲ្យពាលតាម
ជាកូនចៅនរណាម្ដេចមិនហាម
បណ្ដោយតាមចិត្តកូនឲ្យខូចឈ្មោះ ៗ
ខ្ញុំឃើញគេឧបាការគួរស្អប់
គេចត្រឡប់បាកចេញពីទីនោះ
ដើរមកក្រៅមើលភ្លើងគេអុជប្រុះ

ចំដើរឆ្ពោះទៅស្ដាប់ភ្លេងបារាំង ៚
ឃើញទាហានខ្មែរយើងរូបក្មេងៗ
ឈរដំកង់តាំងលេងនៅមុខរាំង
មាននាយត្រួតបន្ទឺសព្ទដូចស័ង្ខ
ស្គរមួយតាំងក្រាំងៗ តាមចង្វាក់ ៚
ត្រែតូច ៗ ដូចក្លុយខ្លុះវៀនជុំ
ត្រែធំ ៗ រំភ្លាយដូចគេធ្លាក់
កាន់សៀវភៅរាល់ដៃផ្ចុំមើលថ្នាក់
ខិត ៗ ដាក់តាមចង្វាក់ព្រមៗគ្នា ៚
សែនពិរោះសព្ទត្រែសេលានកង
ចប់ចុះម្តងឡើងថ្មីបំភ្លៃឃ្លា
មេឡើងហែបកូនអែបប្រសព្វគ្នា
ស្ដាប់ហាក់ជាភ្លេងកុម្ពណ្ឌលាន់ព្រុសាយ ៚
ពួកបារាំងរៀបតាំងលៀងសុរា
សព្វក្រយាអាហារគ្រឿងពីនាយ
បោយបំរើទាញផ្ចិតជាប់កាយ

កំសាន្តកាយដោយក្មេងលេងប្រគំ ៗ
លុះម៉ោងជប់ជួនយប់រួចការលៀង
ពួកបារាំងព្រមព្រៀងទាំងតូចធំ
នាំគ្នាដើរមើលការទីប្រជុំ
សែនភិរម្យលោះលាយសប្បាយក្រៃ ៗ
ពួកអ្នកលេងដើរវិញបារស្វា
ខ្លះចូលស្រាក៏ទិញស្រាអាស្រ័យ
ពួកអ្នកលក់ឃើញមនុស្សទិញច្រើនក្រៃ
តម្លើងថ្លៃយកកម្រៃលើសប្រក្រតី ៗ
លុះព្រឹកឡើងថ្ងៃជ្រេព្រះទិនករ
បមក្ខធរចេញគង់ព្រះពោងថ្មី
ព្រមវង្សានុវង្សក្រុមកុង្សុយ
ទាំងមន្ត្រីតូចធំជុំត្រៀបត្រា ៗ
មានតម្រាស់ត្រាស់ឲ្យចាត់ចែងទី
រាជពិធីចំរើនព្រះជន្មា
មន្តព្រះសង្ឃសូត្រមន្តតាមវេលា
ចំនួនគ្រប់ជន្មាចិតសិបបាយ ៗ

លោកមង្គលទេពាចារ្យធំបំផុត
ចំណែកខាងធម្មយុត្តិសង្ឃទាំងឡាយ
លោកមហាវិមលកុបកិប្រាយ
ជាពួកខាងមហានិកាយអធិបតី ៗ

ព្រមព្រះគ្រូជាគណៈក្រៅ
សឹងផ្ដុំនៅនាចុងព្រះរោងថ្មី
ថ្វាយពុទ្ធមន្តចំរើនពជសួស្ដី
មង្គលកិច្ចឲ្យស៊ីសុវត្ថិ ៗ

បក្រពង្សទ្រង់តាំងលោកពុទ្ធវង្ស
ប្រោសឲ្យគង់ក្នុងដែននគរវត្ត
ខាងអាចារ្យបាសកបេះបរិយត្តិ
គឺអាចារ្យអ៊ុមគាត់បេះសាស្ត្រា ៗ

ប្រោសប្រទានគ្រឿងយសអាចារ្យអ៊ុម
ឡើងជាធំទីសទ្ធម្មមេធា
ជាបាងហ្វាងខាងពួកត្រៃវិជ្ជា
ប្រចាំនានគរវត្តប្រាកដហោង ៗ

លុះពេលយប់អុជកាំជ្រួចរន្ទា
ភ្លឺគោហៀនូវគ្រឿងដទៃផង
ពួកល្ខោនក៏រាំដូចសព្វដង
អស់មនុស្សផងមកមើលដូចសព្វគ្រា ៗ

លុះដល់ថ្ងៃដប់ប្រាំវេលាព្រឹក
មានពិធីផឹកទឹកព្រះសច្ចា
ប្រជុំពួកមន្ត្រីសេវកា
ព្រាហ្មណ៍ហោពជាជំក្នុងពិធី ៗ

តាំងនៅនាព្រះភ័ក្ត្រនៃព្រះពាន់
ព្រះបរខ័ណ្ឌក៏ទ្រង់យាងចរលី
នាំព្រះវង្សកុង្សីយ៍ក្រុមយោធី
ឡើងកាន់ទីប្រាង្គធំប្រជុំការ ៗ

លោកសក្តិប្រាំសក្តិបីព្រៃនគរ
ក៏ស្មោះសរបរតាមព្រះករនាថ
តាំងនាម៉ឺនក្នុងក្រៅគ្រប់មុខងារ
ទទួលការតានទឹកប្រណិធាន ៗ

លុះជុំព្រមព្រាហ្មណ៍ហោរសូត្រពិធី
ប្រណិធានតាមទីពីបុរាណ
កូរអាវុធចុះជាទិព្វញាណ
ស្ដេចទើបរាជទានក្រុមនានា ។
ចៅហ្វាយខែត្រសៀមរាបព្រះដំបង
ជានាយកងក្រុមក្រៅព្រះរដ្ឋា
លោកកុង្សីយអធិបតីក្នុងសីមា
ទទួលទឹកព្រះសច្ចាការកិរិយ ។
លុះស្ដេចពិធីទឹកសម្បថ
បក្រពត្រក៏ទ្រង់គន់ប្រជុំ
គូវែរណែររ៉េស៊ីដងត៍កំពង់ធំ
គាល់ប្រជុំជំនុំតាមកិច្ចា ។
ទ្រង់ឲ្យហូតនាទីអាជ្ញាហ្លួង
នាយក្រសួងសក្ដិបរាជអាជ្ញា
ទាំងលោកជំកុម្មីសែរតស្រុក
ឲ្យផ្លាស់វិលភាគក្នុំពេញហោង ។

យកលោកធំរ៉េស៊ីដង់ត៍កំពង់ស្វាយ
ឡើងជានាយកុម្មីសែរព្រះដំបង
មួយរាជការសុខទុក្ខអស់ពស្ត្រផង
ទៅហ្វាយខែត្រព្រះដំបងជាឥស្សរ ៗ
លុះប្រជុំរួចស្រេចស្តេចវន្ទីយ៍
អញ្ជលីលារូបព្រះសាស្តា
ទ្រង់យាងបាទចេញតាមទ្វារបច្ឆិមា
ព្រមព្រះវង្សពង្សាហែចេញថ្កាន ៗ
ពួកអ្នកថតចាំថតព្រះរូបទ្រង់
ឲ្យជាប់ជុំទាំងវង្សព្រះប្រាង្គស្ថាន
ខ្ញុំឃើញគេពេញកោតគេចំណាន
ថតយកបានព្រះឆាយកាយកូបរ ៗ
លុះយាងដល់កនហាលមុខព្រះលាន
ពួកទាហានអាវុធសលុតឈរ
ស្តេចឡើងគង់ព្រះសលៀងរាជបវរ
ពួកអ្នកសែងហែចរចូលវាំងថ្មី ៗ

លុះដល់ស្រេចស្តេចចូលព្រះរោងធំ
ថ្វាយបង្គំព្រះសង្ឃទាំងចាស់ខ្ចី
អង្គាសភត្តភេសជ្ជៈបាយចំណី
ក្រុមសង្ឃការីចាត់ការចង្ហាន់សង្ឃ ៗ
ព្រះសង្ឃសូត្រទទួលរាជភត្ត
តាមកំណត់ពេលនោះថ្ងៃទៀបត្រង់
សូរេចកិច្ចសង្ឃលាព្រះចក្រពង្ស
ស្តេចក៏ទ្រង់ចូលកាន់ព្រះពន្លា ៗ
លុះដល់ពេលសូរិយោជ្រេស្រទន់
ឲ្យនិមន្តព្រះសង្ឃសង្គាយនា
ចំនួនអង្គមួយរយដោយគណនា
លោកទេសនាត្រៃបីតាមព្រេងព្រឹទ្ធ ៗ
ទី១ បាលីវិន័យធរវត្តតាមិម
អានទូគឺរាបាឡគិមវត្តពិកិត
ទីកស្សបព្រះគ្រូវត្តបូរពិត
ចៅគណសង្ឃស្ថិតស្រុកសៀមរាប ៗ

សង្គាយនាបឋមតាមវេណី
ក្នុងគម្ពីរបិដកតាមសភាព
លុះចប់ចុះពេលថ្ងៃស្រទន់ទាប
សង្ឃបានលាភក៏វិលវត្តអាត្មា ៗ
ពេលយប់នោះមានការលេងអាប៉េ
ក្បួនយីកេកំឡុកបកកាសា
ពួកអ្នកស្រុកក៏មកមើលត្រៀបត្រា
សែនមហាសប្បាយលោះលាយក្រៃ ៗ
លុះដល់ថ្ងៃមួយពេចរួចពិធី
ឲ្យចាត់ហែព្រះគម្ពីរបិដកថ្ងៃ
ចូលតម្កល់តាំងទុកនៅហោត្រៃ
សម្រាប់នៃកុលបុត្រអ្នកសិក្សា
ថ្ងៃពីរពេចព្យុថាចក្រពង្ស
ក្រសាលស្រះស្រង់ទិសបច្ចិមា
ឯខ្ញុំបាទក៏នាំកៀនយាត្រា
ទៅមើលក្រុងគាភនគរធំ ៗ

លុះដើរដល់ទូរគមភ្នំប៉ាំខែង
ព្រៃត្រសុំបាំងសែងសែនកិរម្យ
ជើងគិរីមានសិង្ហតាំងពីរមុម
ឈរចាំអែបែរចំទិសបូព៌ា ។
សិង្ហបាសាណបុរាណលោកសំអាង
មើលដូចយ៉ាងសិង្ហសត្វរាជសីហា
ធាត់ក្រអួនខ្លួនក្រអាញក្រាញដូចខ្លា
ចំអែងស្មា ឈរអើតចំទើតជើង ។
ខ្ញុំយល់សិង្ហឈរនឹងពុំកម្រើក
ចង់តែលើកយកមកទុកស្រុកយើង
តែធំហួសផុតការលើកមិនឡើង
នឹងចចើងលើកយកពុំរួចឡើយ ។
អនិច្ចាសិង្ហអើយសិង្ហបាសាណ
ខ្ញុំយកទៅពុំបានណាសិង្ហអើយ
ឯងនៅចុះឲ្យសុខកុំទុក្ខឡើយ
កម្មសិង្ហហើយមកនៅក្នុងព្រៃស្ងាត់ ។

បើសិង្ហឯងរស់ពិតជីវិតមាន
គួរជានៅស្មសានសន្តានសត្វ
ស្វែងអាហារលៀងជីពពុំសូវខាត់
នេះមកបាតវិញ្ញាណមានតែប្រាណ ៗ
ទឹងដើរទៅទីណាក៏ពុំកើត
នៅតែឈរចំអើតប្រចាំដាន
ស្តាយអើយស្តាយរូបសិង្ហលោកបុកណា
បោលក្នុងស្ថានស្មសានអនាថា
ខ្ញុំសម្តេចរូបសិង្ហប្រឹងឡើងភ្នំ
ថ្មតូចធំជិតជុំជាន់រអា
ខ្ពស់ត្រឈឹងខំប្រឹងឡើងប្រាប់
លុះដល់នាកំពូលគិរីឋាន ៗ
លើបារែខងលោកតែងជាសថូប
មានរួតរូបប្រាំជាន់ជាដាន ៗ
ខាងបូព៌ាមានប្រាង្គតាំងបួនស្ថាន
វិចិត្រជាយបាសាណឥដ្ឋសិលា ៗ

ខាងមុខប្រាង្គមានឡ្យាយព្រះបាទព្រះ
វាលស្រឡះពុំមានគ្រឹះលេខា
ដាប់ទម្លុះធ្លុះបុះក្នុងសីលា
ខាងលើលោកតាំងជាវិហារបាំង ៗ
តែវិហារនោះឯងលោកតែងថ្មី
ធ្វើដោយឈើដោយបុស្សីប្រក់ស្បូវក្លាំង
ពីបុរាណមានតែរណ្ដៅតាំង
ថ្មរឹងតាំងនៅបណ្ដូលគោលសិលា ៗ
ពុទ្ធបាទខ្នាតជ្រៅជំរៅបាត
បាយហាត់ខ្នាតបណ្ដោយបួនហត្ថ
ទទឹងសោតពីរហត្ថជាមាត្រា
ក្នុងបាតាលាយលក្ខណ៍កងចក្រជុំ ៗ
លោកវិចិត្របិទមាសវិលាសលឿង
មើលរុងរឿងគួរយើងឡើងបង្គំ
សព្វថ្ងៃមានលោកយួនគេជាធំ
នៅថែទាំពីកក្ដីរក្សាស្ថាន ៗ

ខ្ញុំយល់ព្រះពុទ្ធបាទអនាថបិត្ត
គិតដល់អង្គអគ្គនិដ្ឋព្រះទ្រង់ញាណ
កាលព្រះអង្គស្តេចនឹងចូលនិព្វាន
ព្រះទ័យមានមេត្តាដល់នរជាតិ ។
សត្វឯក្រោយពុំបានយល់សាស្តា
បានទាន់តែសាសនាបរមនាថ
ទើបប្រតិស្ឋានព្រះពុទ្ធបាទ
និងទុកឲ្យប្រោសអស់សត្វផង ។
ទព្រះគុណបានបុណ្យលន់វិសេស
ទ្រង់កំចាត់កិលេសជាគ្រឿងហ្មង
បាននិព្វាននៅមានព្រះទ័យចង
តម្កល់បាទតាងស្នងព្រះពុទ្ធអង្គ ។
ទុកឲ្យសត្វឯក្រោយបានបូជា
ជាផ្លូវទៅសួគ៌ាឋានទេពទ្រង់
សាងកុសលទាល់បានកាត់ពគបង់
មិនយូរលេង់គង់បានឋានសុខា ។

វេលានេះខ្ញុំមកដោយការខាត់
ពុំមានអ្វីប្រតិបត្តិបាត់បូជា
មានតែដៃទាំងដប់ខ្ញុំវន្ទា
ចិត្តវាបាបូជាក្នុងគ្រានេះ ។
ឱព្រះបាទនេះជាព្រះជាន់ឬ
ឬមួយគឺគេសាកទុកទេអេះ
ក្នុងតម្រាពុំមានតាំងភ្នំនេះ
បើតាមរិះយ៉ាងសំណាកគេសាកថ្មី ។
បញ្ចាបាទទាំងប្រាំសឹងមានដាន
ឈ្មោះគេមានគ្រប់ស្ថានទាំងប្រាំទី
ភ្នំបាខែងពុំមានក្នុងព្រះគម្ពីរ
ជាក់ជាទីកើតក្រោយដោយនិយម ។
ខ្ញុំវន្ទាព្រះបាទស្រេចលាចុះ
តម្រង់ឆ្ពោះកាត់ទៅមើលនគរធំ
ផ្លូវថ្លាថ្នល់សឹងឈើម្លូបត្រសុំ
គេរំលំកាត់ត្រង់នគរ ។

លុះដើរដល់ខ្លោងទ្វារនគរធំ
សុទ្ធសឹងដុំថ្មជិតប្រកិតគ្នា
កំពូលខ្ពស់សិនសេសដោយគណនា
ចម្លាក់ជារូបទេពប្រណម្យដៃ ។
កំពូលលើឈើដុះទម្លុះបាក់
ថ្មរុះជ្រុះធ្លាក់ខ្ចាយរាយដោយព្រៃ
នៅតែកង់ដូចយ៉ាងព្រះប្រាង្គជ័យ
ចូលអាស្រ័យចុះមនុស្សជាងរយនាក់ ។
ផ្ទៃកំពែងតែងដោយថ្មក្រៀមក្រាស់
បូកដីជាសពាសប៉ះឡើងថ្នាក់ៗ
កម្រាស់ក្រាស់ប្រមាណបីព្យាមជាក់
ជំអនគ្បូវែងអនេកលើសគណនា ។
ក្រៅនគរតែងប្ចូកសិណសាយ
មើលវែងឆ្ងាយឧបអមនគព
តែឥឡូវស្បាតជិតដោយព្រឹក្សា
បិទគ្គាកើតជាត្រឹបតាប់តាន់ ។

មើលខ្លោងទ្វារពេណ៌ នាគុំអស់ក្បួន
ពេលកំដួនទៀបទោរព្រះសុរិយ័ន
ខំកាត់ចូលបូរីដោយបន្ទាន់
ដល់ប្រាសាទបាយ័នរាជភិរម្យ ។
ប្រាង្គបាយ័នលោកសាងជាប្រាង្គមូល
មានកំពូលប្រាង្គចេញជាបួនមុម
ក្នុងកំពូលមួយៗ ឆ្លាក់រូបព្រហ្ម
បួន ៗ ជុំគ្រប់ប្រាង្គប្រូងប្រាងក្រៃ ។
ឯរោងទងជុំវិញជ្រុងកែងកាត់
ទ្វារលោកចាត់កាត់មួយទ្វារមួយនៃ
ក្នុងឡប់ឡែបែរមុខទៅទីទៃ
ចតុរស្សស្មើផ្ទៃបីជាន់សាយ ។
ឱប្រាង្គនេះមើលទៅសម្បើមលន់
ខ្ពំគន់ ៗ គិតទៅគួរតែស្តាយ
ប្រាង្គនេះតើជាក់អ្វីពីព្រេងនាយ
តាមបរិយាយគឺជាក់ភាពយោនី ។

គឺកាលដើមកាន់សាសនាព្រាហ្មណ៍
ប្រព្រឹត្តតាមតម្រាព្រះសូលី
យកយោនីឧមាភោគវតី
ជាសិរីសួស្តីតាំងបូជា ៗ
គេយល់ថាមនុស្សយើងលើធរណី
កើតចេញពីយោនីនាងឧមា
នាងជាម្តាយមានគុណទាំងលោកា
ទើបនាំគ្នាសាងជាកំណើតហោង ៗ
បើមានការមង្គលចំរើនបុក្ស
ព្រាហ្មណ៍យកទឹកស្រោចកាពបង្ហូរត្រង
មកប្រសិទ្ធិស្រោចអស់មហាជនផង
បំបាត់ក្តីសៅហ្មងបាកតន្ទ្រិយ៍ ៗ
ភាសាព្រាហ្មណ៍គេកាន់តម្រាសៃយ
ទើបកៃខចម្លងរូបយោនី
សាងប្រាង្គនេះតាំងជាមន្ទីរទី
លោកសញ្ញាឲ្យហៅថាបាយ័ន ៗ
ឯសព្ទ "បា" នោះថាមូតមួយ ៗ

តាមតម្រួយសព្ទ "បា" គឺមួយខណ្ឌ
យ័ន សព្ទនេះពុំមែនជាលេខយន្ត
កុំប្រកាន់យន្តលេខតាមកាសិត ៗ
សព្ទ "យ័ន" នេះគឺជាភាសាព្រាហ្មណ៍
មានក្នុងក្បួនសព្ទនាមថ្ងៃសំស្រ្កឹត
ខ្ញុំមើល ៗ បាយ័នក៏តូចចិត្ត
នឹកអាណិតដល់ក្សត្រពីបុរាណ ៗ
លោកមានបុណ្យកសាងប្រាង្គបាយ័ន
ទុកក្នុងខណ្ឌនិវេសន៍នៃក្សត្រក្សាន្ត
មានទេសកាលក៏ឡើងប្រតិស្ឋាន
ស្រោចស្រប់ប្រាណដោយទឹកនាងឧមា ៗ
សែនរុងរឿងថ្កើងបុណ្យថ្កើងកេរ្តិ៍ឈ្មោះ
កិត្តិសព្ទឮសុសសព្វក ព
បរទេសពជគោតខ្លាចឡើងវន្ទា
ពស្ត្រប្រជាសឹងក្សាន្តសម្រាន្តកាយ ៗ
ឥឡូវនេះនិវេសន៍ទៅជាព្រៃ

ទាំងប្រាង្គជ័យក៏ដល់ក្តីអន្តរាយ
ឃើញតែស្នាដៃធ្វើបែបឡែបខាយ
ស្តាយអើយស្តាយមិនគួរមកខ្ទេចណា ៗ
ទីខាងជើងមានវត្តលោកសង្ឃនៅ
ព្រះនាមហៅព្រះង៉ោកលោកលេខា
ឱព្រះង៉ោក ៗ មែនឬយ៉ាងណា
ឮគេថាយល់ជាអស្ចារ្យក្រៃ ៗ
ខ្ញុំទៅមើលពុំឃើញព្រះលោកង៉ោក
គិតប្រយោគយល់ថាព្រះម្ចាស់ថ្លៃ
រូបព្រះធំលន់លើសព្រះដទៃ
ឯងរំពៃមើលដុបដូចង៉ោកមក ៗ
វត្តមួយខាងបស្ចិមគ្មានលោកសង្ឃ
កុដិវិហារដូចបង់គ្មានទីជ្រក
វត្តនោះឯងគេហៅវត្តគោកធ្លក
តនោះមកវត្តត្បូងបោលដូចគ្នា ៗ
វត្តនោះហៅព្រះឥន្ទ្រទេពកោសី

អង្គព្រះជីវ៍ក៏ធំសមរូបា
កុដិវិហារបាំងព្រះគ្មានឡើយណា
អនិច្ចាមើលទៅសម្ដេចក្រៃ ៗ
ឱអង្គព្រះឥន្ទទេពកោសីអើយ
មិនគួរឡើយមកនៅកណ្ដាលព្រៃ
អាប់ពាសីដោយសែងហែងដោយថ្ងៃ
ទីអាស្រ័យពុំមានក្សាន្តព្រះកាយ ៗ
បើព្រះអង្គទៅគង់ស្រុកខ្ញុំ"
ខ្ញុំនឹងសាងសាលាវិហារថ្វាយ
តាំងគ្រឿងតុគ្រឿងតាំងឲ្យឆើតឆាយ
ដូចជាព្រះតាំងឡាយស្រុកព្រះដំបង ៗ
គ្រាន់និមន្តជូនលើកទៅពុំបាន
ព្រោះធំហួសប្រមាណដូចកន្ទង
បើអង្គតូចទៅក៏នឹងពីបរង
ដាក់ដឹកជូនមកស្រុកទុកបូជា ៗ
ឱលោកណាសទ្ធាសាងព្រះនេះ

ម្តេចមិនរិះត្រិះមើលដោយបញ្ញា
កាលស្រុកដីមិនផុតក្តីអនិច្ចា
មកគិតថានិច្ចំតាំងទៀងទាត់ ៗ
កាលប្រទេសរុងរឿងធ្វើតាមចិត្ត
ដល់ប្រទេសវិបរិតកើតវិបត្តិ
ព្រះដីវ៍ធំទឹងរំកិលក៏កើតខាត់
តោងចាំកាត់ចិត្តចោលទុកប្ទេះណា ៗ
បើយ៉ាងព្រះតូច ៗ ល្មមយករូប
តែដុល់ស្រុកខាត់ខូចដូចម្តេចម្តា
ចង់រំលៀកក៏បានដូចចិត្តា
ចុះតម្រាធំខូចតូចមិនខាត់ ៗ
ដូចពស្រ្តទាសតាំងឡើងជានាហ្មឺន
ប្រព្រឹត្តកឹនហួសការពជបញ្ញត្តិ
ទឹងដកចេញចាកទីក៏មិនខាត់
តែមហាក្សត្រវិបត្តិដកពុំបាន ៗ
តោងចាំនៅទៅតាមយថាកម្ម

ទុក្ខក៏ទ្រាំទោសក៏ទ្រាំទម្រាំក្សាន្ត
ដូចព្រះអង្គឥន្ទ្រទេពជាបែបមាន
ក្សាន្តពុំបានព្រោះប្រាណធំលើសគេ ។
អនិច្ចា សាសនាព្រះជិនវង្ស
ពុំស្ថិតស្ថេរបេរលង់ក្នុងនគរ
ជាបុណ្យបាបអ្វីពីបុរេ
បានជាប្រែប្ដូរព្រៃដូច្នេះ ។
ស្រុកនេះសូន្យតើសូន្យពីកជ្យណា
ពង្សាវតារតម្រាឯណាអេះ
នឹងបានមើលឲ្យដឹងកជ្យនោះនេះ
ខ្ញុំនឹងត្រិះឲ្យត្រូវតាមរបាក្សត្រ ។
ខ្ញុំគន់មើលវត្តបីស្រេចចរចើរ
ទៅមើលកជមន្ទីរបក្រវត្តិ
នៅខាងជើងព្រះអោកលោកបែងចាត់
ខឿនចង្អាត់ខ្វាត់ខ្វែងវែងវឹង ។
ប្រាង្គប្រាសាទបែកបាក់ធ្លាក់ខ្ទេចខ្ទី

នៅតែទីគ្រឹះក្រោមកាត់ទទឹង
មុខប្រសាទស្ពានពបភាពផាបឹង
ជើងជណ្តើរដើរមានសិង្ហឈរប្រឹងប្រែង ៗ
ឯផ្ទៃផ្តែឆ្លាក់រូបរឿងក្បួនខេន
ជិះគជេន្ទ្រហៃស្ដជាជួរវែង
ខាងជ្រុង ៗ រូបគ្រុឌឈរចាំទែង
ខ្វះសម្តែងតាប់រាំសុក្រីក្រាយ ៗ
មុខព្រះពភនមានប្រាង្គជាកាត់ ៗ
ហោប្រាសាទសួព្រ័ត្រខ្ពស់ត្រសាយ
ខ្ញុំយល់ ៗ នឹកកោតគេអម្បាយ
ប្រាង្គខ្ពស់ឆ្ងាយចង់ព្រ័ត្រហ៊ានសួបាន ៗ
ទីខាងក្រោយប្រាសាទហោបាពួន
មើលក្បាច់ក្បួនឡប់ឡៃជាជាន់ៗ
ឥបាពួនទួននាងក្នុងវាំងស្ពាន
ចូលកំសាន្តលេងពួនបន្ទែងអង្គ ៗ
ទីខាងជើងខ្វាងទ្វារមានគ្រឹះគ្រែ
ជាថ្នាក់ហៃសឹងរួតហួតហៀនហង្ស

លើមន្ទីរសាងរូបចក្រពង្ស
ស្តេចគំលង់គង់នៅប្រចាំទី ។
ខ្ញុំយល់រូបព្រះបាទសន្ធចក្រ
គេសាកផាក់ជាឡាក់រាជធានី
កើតសម្តេចវេទនាសល់សែនទ្វី
មិនគួរទើមកកើតវិបត្តិច្នេះ ។
ព្ទតម្រាបរម្យកពីបុរាណ
ជាព្រះចមក្សត្រក្សាន្តនគរនេះ
ប្រហារនាគឈាមនាគផ្សព្វផ្សាយឆេះ
ត្រូវព្រះកាយកើតប្រែះប្រែជាឃ្វន់ ។
មើលពុំជាវេទនាពន់ប្រមាណ
ឥសីសានមកប្រោះចក្រពង្ស
ស្តេចពុំជឿតាមពាក្យឥសីសង្ឃ
ទើបព្រះអង្គបង់ការអេសារកាយ ។
ឥសីខឹងផ្តាសារាជនិវេសន៍
ទៅប្រទេសកំលុះក្តីអន្តរាយ

បានជាទីស្រុកនេះកើតខ្វាត់ខ្វាយ
ដោយបរិយាយដៅ ៗ ពុំពិស្តារ ។
ខ្ញុំត្រិះ ៗ នឹកគិតះស្ដេចគំលង់
ព្រះទ័យទ្រង់មានៈអហង្ការ
កើតហេតុអ្វីនឹងនាគទើបប្រហារ
ឲ្យខូចស្រុកអសារស្នាដៃខ្លួន ។
គួរឬក្រុងនគរសេប្រទេសធំ
ប៉មកំពែងជិតជុំដ៏មាំមួន
សត្រូវណានឹងអាចចូលមកក្នុង
តែគិតទៅចុះក្បួនព្រះត្រៃលក្ខណ៍ ។
សព្វសង្ខារមិនថាតាំងស្រុកដី
ទួបូរីសាយសព្វគ្រប់ដំណាក់
ទុកជាបេះយ៉ាងណាក៏គង់ធ្លាក់
អញ្ជើញអ្នកមើលស្ដាប់ចាប់អារម្មណ៍ ។
នគរធំបរមបុកណាពង្ស
មើលគួរខ្លាចសឹងព្រៃស្រោងស្រាងជុំ

មានអ្នកស្រុកតាំងនៅជាដុំ ៗ
រកស៊ីតាមនិគមអ្នកជនបទ ៗ
រយៈផ្លូវទៅដល់នគរធំ
ដោយនិយមរាស់ពីនគរវត្ត
ប្រមាណបានកៅសិបសិនប្រាកដ
ចូរកំណត់កត់ចុះលោកពល់គ្នា ៗ
ក្រែងបានទៅទឹងឆាយដឹងទិសទី
ពជធានីបុពណទិសឧត្តរ
តែឥឡូវបារាំងគេកាប់ឆ្ការ
ទំនងជាយូរទៅគង់សប្បាយ ៗ
ខ្ញុំដើរគន់ដើរគត់នគរធំ
ពុំបានជុំនគរទេលោកាយ
ពេលក៏ជួនសុរិយេជ្រេព្រះឆាយ
ក៏រៀបកាយវិលមកសៀមរាបវិញ ៗ
លោកចៅហ្វាយលោកធំលោកសក្តិបី
សូមទេចការចក្រីក្រុងភ្នំពេញ

បង្គំលាវិលព្រះដំបន់វិញ
ខ្ញុំក៏អស់ក្ដីម្នេញការលោកីយ៍ ៗ
ដល់មកស្រុកសាន្តសុខឥតទុក្ខា
ដោយអំណាចបក្រាគ្របកេសី
ទាំងគុណកែវរតនត្រៃថ្លៃទាំងបី
ជួយចំរើនពសីឥតហ្មងសៅ ៗ

រឿងនិពសប្រកាសតែប៉ុណ្ណោះ

សូមទុកស្នេះប្រារព្ធបញ្ឈប់នៅ
គ្រាន់ទឹងតែងតអង្គព្រះបមបៅ
កាលស្ដេចនៅពុំទាន់វិលភ្នំពេញ ៗ
ខ្ញុំលាហើយពុំដឹងក្រោយយ៉ាងណា
រាជកិច្ចាពុំទាន់ប្រកាសចេញ
ហេតុដូច្នោះទុកឲ្យប្រាជ្ញភ្នំពេញ
គេតែងចេញតរឿងព្រះបក្រី ៗ
ខ្ញុំឥន្ទាចារ្យចែងតែងពុំបាន
ព្រោះគ្មានជានលំអានយោគសេចក្ដី

ហេតុនោះសូមមេត្តាប្រោសប្រណី
ខ្ញុំបញ្ចប់សេចក្ដីតែប៉ុណ្ណេះ ។
　　សូមទោសលោកមេធីកវីជាតិ
កុំឧបវាទពាក្យកាព្យខ្ញុំតែងនេះ
សូមតម្រូវឲ្យត្រូវតាមលោកចេះ
បើមិនផេះកុំបើកលើកចូលចេញ ។
កុំប្រមាទពាក្យកាព្យថាតែងងាយ
យារមុខតាមនិយាយដាក់បំពេញ
បើមិនចេះពាក្យស្រួលខ្យល់ "រ" មិញ
ឲ្យដេកវិញជាជាងកុំតែងឡើយ ។
មួយបើអ្នកឯណាចង់ចម្លង
តាមទំនងនិពសនេះលោកអើយ
ចូររាំងខ្យល់ "រ" "ល" ជាត្រើយ
តែបាត់ហើយខូចដល់ខ្ញុំអ្នកតែង ។
មួយស្រៈ "ៃ" បំភ្លៃនឹងស្រៈ "ៈ"
វិសជ្ជនីយខ្យល់ "ស" លោកសម្ដែង

កុំឲ្យចូលយារមុខទន្គុកឯង
ឲ្យនៅតាមកន្លែងទីដោយខ្លួន ។
ពាក្យសំយោគការន្តូវិធីសព្វ
ចូលលំដាប់ពីប់គ្នាទៅតាមជួន
យោគសេចក្ដីតាំងមុខឲ្យមាំមួន
រកចុងជួនមេកាព្យសភាពអើយ ។

ចប់